- Reçu le 10-9-...
INDOCHINE FRANÇAISE
DÉPÔT LÉGAL

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៣ លេខ ១

ខែ កញ្ញា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥១ - ១៩៥២

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K_2
1951 - 1952
(1)

# ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

### បញ្ជីរឿង ទំព័រ


វិធីបង្រៀនអក្សរបែបថ្មីនៅកុមារដ្ឋាន ៣

ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា ១៩

មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា ២៦

កុមារដ្ឋាន - បរិវច្ឆណដ្ឋាន ភាសា ៣៥

មជ្ឈិមដ្ឋានទី២ - ឧត្តមដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ - ធរណីមាណសាស្ត្រ ៤១

អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ នព្វន្ត ៥២

មជ្ឈិមដ្ឋានទី ១ និងអាទិកដ្ឋាន - ធរណីមាណសាស្ត្រ ៦៤

បរិវច្ឆណដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ កុមារដ្ឋាន ៦៦

មជ្ឈិមដ្ឋានទី ២ - ឧត្តមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការោគ ៧៥

អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការោគ. ៨៦

បរិវច្ឆណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការោគ ៩៣

លោកនិតី សំរាប់ ៤ ថ្នាក់ ១០១

មេសូត្រត់មាត់ ១០៤

សូមសាស្ត្រាចារ្យ ល្បងវិធីថ្មីនេះមើលតាំងពីបវេសនកាលនេះទៅ

# សេចក្ដីណែនាំ

លោកជាគ្រូបង្រៀនត្រូវរកក្រដាសក្រាស់ពណ៌សពន៍ ៤ ជ្រុងទ្រវែង បណ្ដោយ ១៤ ស.ម. ទទឹង ១០ ស.ម. ។

១)- យកមកបោះប្រហោង ៤ ជ្រុងទ្រវែង ទទឹង ៥ ស.ម. បណ្ដោយ ៦ ស.ម. ឲ្យចំកណ្ដាលក្រដាស ដើម្បីទុកសរសេរលើផ្ទៃក្រដាស, ម្ខាងស្រៈមួយ លើផ្ទៃម្ខាងទៀតស្រៈមួយទៀត ធ្វើបែបនេះឲ្យគ្រប់ស្រៈទាំងអស់ ដូចមានគំរូខាងក្រោមនេះ



២)– យកមកសរសេរព្យញ្ជនៈ ១ តួម្ខាង ឲ្យចំកណ្ដាល ល្មមនឹងប្រហោងដែលចោះធ្វើស្រះនោះ ដូចមានគំនូរខាងក្រោមនេះ ។




៣)– ឧបមាដូចជាបង្រៀនអក្សរ “ ត ” លោកជាគ្រូត្រូវ

ក – សរសេរតួអក្សរយ៉ាងធំនៅលើក្ដារខៀនបង្ហាញសិស្ស ។

ខ – នាំសិស្សឲ្យវាសតួអក្សរនេះនឹងដៃទទេ ។

គ – ចាត់សិស្សម្នាក់ ឲ្យទៅសរសេរនៅលើក្ដារខៀនដើម្បី ឲ្យសិស្សឯទៀតកែ ឲ្យបានត្រឹមត្រូវឡើង ។

ឃ – ឲ្យសិស្សទាំងអស់គ្នាសរសេរលើក្ដារឆ្នួនលើកបង្ហាញគ្រូ ។

បើសិស្សណាសរសេរមិនត្រឹមត្រូវ លោកជាគ្រូត្រូវបង្គាប់ឲ្យសិស្សនោះ កែឲ្យបានគួរសមឡើង ។

## របៀបប្រើព្យញ្ជនៈនិងស្រៈដែលសរសេរលើក្រដាស់ក្រាស់

១– ឧបមាដូចជាបង្រៀនបំបែកអក្សរ “គ” លោកជាគ្រូត្រូវ :

ក– លើកស្រៈ “ េ ៀ” បង្ហាញសិស្សហើយសួរថា:នេះស្រៈអ្វី ?

ខ– យកក្រដាស់ដែលសរសេរតួអក្សរ “គ” មកដាក់ពីក្រោយ ក្រ-ដាស់ដែលសរសេរស្រៈ “ េ ៀ” ដូចបែបខាងក្រោមនេះ



គ – សួរសិស្សថា: នេះគេអានថាដូចម្ដេច ? ឆ្លើយថា: ( គៀ )

លោកគ្រូត្រូវសរសេរឲ្យច្បាស់ព្យាង្គនេះនៅលើក្ដារខៀនបញ្ឈរ ។

យូរៗម្ដង, គ្រូត្រូវប្រើរបៀបនេះ ឲ្យសិស្សរើសរកស្រៈមកផ្សំនឹងតួព្យញ្ជនៈ ដើម្បីឲ្យកើតជាព្យាង្គណាមួយតាមចិត្តគ្រូរើស ។

២ — ឧបមាដូចជាបង្រៀន (តោ) — (តុ) — (តៅ) (តែ) ។ល។ លោកជាគ្រូត្រូវធ្វើតាមរបៀបខាងលើនេះ ។

---

# អំពីស្រៈ

## មេរៀនទី - ១

អ អា

## មេរៀនទី - ២

អិ អី

## មេរៀនទី - ៣

អឹ អឺ

## មេរៀនទី - ៤

អុ អូ អួ

មេរៀនទី ៥

អើ អឿ អៀ អេ

មេរៀនទី ៦

អែ អៃ អោ អៅ

មេរៀនទី ៧

អុំ អំ អាំ អះ

មេរៀនទី ៨

អុះ អេះ អោះ

មេរៀនទី ៩

អឹ អេះ អៅ អុំ អៃ អួ អៀ អើ ។

អាអំ **អា់**អាំ អេះអុះ ៗ អាអុំ អេះអឹ ៗ

អា អាំ អុំ អឹ ៗ

កាលបើបង្រៀនស្រៈខាងលើនេះរួចហើយ គ្រូត្រូវលុបតួ (អ) ចេញ ដើម្បីឲ្យនៅតែស្រៈនិស្ស័យ ។ គ្រូត្រូវហ្វឹកហ្វឺនសិស្សឲ្យចេះអាន ចេះសរសេរ ស្រៈនិស្ស័យទាំងអស់ជាប្រាកដ ។

## មេរៀនទី ១០ ស្រៈនិស្ស័យ

ា ិ ី ឹ ឺ ើ ឿ ៀ

ុ ូ ួ

េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ

ឯព្យាង្គដែលបង្រៀនទាំងប៉ុន្មាន ក្នុងមួយពេលៗ ត្រូវសរសេរមួយម្តងៗ នៅលើក្តារខៀន ។ ឲ្យសិស្សអានព្យាង្គទាំងអស់មាក់ម្តង មួយពួកម្តង ម្នាក់ម្តងរួច ឲ្យអានពាក្យដែលផ្សំបាននឹងអក្សរដែលយកមកបង្រៀន ។

## មេរៀនទី ១១

ក គ

គុ កា គើ គោ គួ កូ គែ កៀ កែ

គោ គែ កែ គា គៅ កែះ កោ(រ) គ គះ កោះ ។

គគេះគគះ កកោះ គគេះគគោះ កកូ(រ) កៅអី គែគោ

អាកោ កកែះ ។

អាគោកកូ(រ)អឺ ។ គាកៅកកេះគុ ។

## មេរៀនទី ១២

ប ហ

បើ ហា បូ ហោ បា ហំ បឹ ហែ បៅ

ហើ បៀ ហៃ បោ ហៅ ។ ហែះ បោះ

ហោះ បោ(វ) ហូ(វ) បបួរ ហៀ(វ) បះ ហៅកៃ

អំបៅ អាហា(វ) បប(វ) បះបោ(វ) ហោហា បំបែ(វ) ។

បប(វ) ហៀ(វ) ។ តាកៅហៅអាកៃ ។ កុំបះបោ(វ) ។

## មេរៀនទី ១៣

ប ឋ

ឋុ ឋៅ ឋា ឋូ បេ បុ បោ ឋា បៃ ឋឹ

ឋំ ឋោ បែ ឋូ ។ ឋាំ ឋោះ បោ(វ) ឋូ(វ)

ឋែ បេះ ឋុះ បៅកៃ បៅ ឋំកា(វ) ប(វ) ឋា ។

ឋឺ តូ បេះ ប(វ) ឋា ។ ឋាំ ឋៅកៃ ឋុះ ។

អាឋៃ ឋាំ បំ កា(វ) ។ តា ឋឿ បេះឋែ បៅ ។

## មេរៀនទី ទី ១៤

ឍ ឌ

ឍូ ឌោ ឌេ ឍូ ឌេ ឌើ ឌុ ឍោ ឌោ ឌៅ ឌា ឌៃ ឌៀ ។
ឌេះ ឍូ(វ) ឌេ ឌោះ ឌុះ ឌុំឌី ឌុំឌៃ បុះឌៃ ឌំបែ ឌំបោ
ឌីកាកោះ ។ កុំឌោះដៃ ។ បែតុំឌាំបប(វ) ។ បីឌាបោះឌីបីឌុំ ។
អាកៅបាំដៃ ។

## មេរៀនទី ១៥

ស ណ

សេ ណៃ សុ ណាំ សៀ ណា សួ ណៅ សុំ ណើ
សោ ណើ សូ ។

ដំណាំ សំដី បំណុះ សំបៃ សំណៅ ស(វ) សៃ
ដំណើ (វ) សំដៅ បំណើ ស (វ) សើ (វ) សំណុំ ។

បីសៅស(វ)សេ(វ)សំណៅ ។ តាសំបេះដាំដំណាំ ។
អាណាសុំបំណើ ។ បីណាសួ(វ)អី ។

## មេរៀនទី ១៦

ឆ ខ ឡ

ឆៃ ខុ ឡេ ឆា ខា ឡោ ឆោ ខោ ឆាំ ឡូ ឆា ខាំ ឡៃ ។

កៅឡោ ឡាំសាំ កែខៃ ឡូឡា ខះក ឡេះឡោះ ឆាឆៅ បោះឡុ ។ ឡៃឡ ។

អាសៅបោះឡូ ។ ប៊ីតោដើ(រ)ឡៃឡប៊ីខៃ ។ បៃឡា ខំដើ(រ)ខោអាឆាំ ។ អាផៃឆាឆៅបៅខាំ ។

អំពីស្រះ (ត)·

| |
|---|
| ឲ្យសិស្សអានឲ្យបានត្រឹមត្រូវល្អ រួចហើយលុបតួ (អី) ចេញ ។ |

## មេរៀនទី ១៧

អិ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ

អែ អៃ អោ អៅ អុំ អំ អាំ អះ ។ អិះ អុះ អេះ អោះ ។

## មេរៀនទី ១៨

គ ភ

គី ភា គួ ភោ គៀ ភី គុ គោ ភូ គេ ភើ គូ ភៃ គុំ ។ ភេ គោ បំភៃ គគី (វ) ភាសាំ គោបុ សំភី តាជា សុភា ។ បៅភុំបាំគេ ។ ចីឡូបេះបីភាសា ។ កុំបំភៃអាគាំ គេបៅ បៅខាំបេះគួ (វ) សំ ។

## មេរៀនទី ១៩

ព ញ

ពោ ញាំ ពី ញើ ពា ញី ពើ ពួ ញោ ពូ ញុ ពៃ ញោ ។

ពុះ ញុះ ពោះ ញាំ ពួ (វ) ញញួ (វ) ពពៃ ពពុះ សំពៅ ពូបៅ ពីសា ពូកែ អំពៅ ពោះគោ ។

អាគាំគូ(វ)ញញួ (វ) ។ តាភេងាំអំពៅ ។ អាសៅថៃ ពពៃញីពី (វ) ។ មៃពៅបេះពីសាបប (វ) ពោះគោ ។

## មេរៀនទី ២០

រ　　　　វ

រេ វៃ រោ វា រ៉េ វោ រួ វេ រា វី រុំ វូ រៃ វៀ ។
រុះ វះ វិះ រេះ វាំ វៃ រៃ វូ (រ) វាបា រំពេ រុះរ៉េ រវៃ របេះ ពីរោះ វេរា រកា របៃ ។

ប៊ីរុំបេះវាំ ។ តាកៅវះពោះគោ ។ ពពែញីដើ (រ) ពវោ ។ សំដីអាឆាំពីរោះ ។ ប៉ៃគាំពូកែវៃអំបោះ ។

## មេរៀនទី ២១

ល　　　　ឈ

លូ ឈោ លឿ ឈុំ លា ឈៀ លី ឈឺ លៃ ឈឿ-
លៀ ឈើ លោ ។

លោះ រលុះ ឈ្លូធ(រ) លីលា ឈឺ លលា ឈើ លលៃ ។

ពូឈ្មុំលីឈើ ។ ប៉ៃគាំឈឺពោះចំខៃ ។ ចៅឆាំលា

តាវា ។ ចៅកែឈ(រ) លើកៅអី ។ កុំដើ(រ) ឈូធ(រ) លើផែ ។

មេរៀនទី ២២

ឃ យ

យោ យ យួ យ យឹ យ យា យំ ររុំ យើ យើ យូ យាំ យី ។

យំ យុំ យូ(រ) គយា(រ) យីកេ យួ(រ) យីហោះ វយះ យោ(រ) យៅ យីអើ សាលាបុំ ។

ខោចៅពៅវយះ ។ គេយុំចៅរុំ ។ អាគាំយិយូ(រ) ។ តាអាំបេះរាំយីកេ ។ គេស(រ) សេ(រ) យីហោ ។ យីអើ ពូឈុំឈីអីដើ(រ) យួ(រ) ដៃ ។

មេរៀនទី ២៣

ម ធ

មើ ធើ មួ ពោ មៀ ធុ មិ ធូ មា ធា មូ ធើ មាំ ។

មេ ធំ ម្ហូ(រ) ធី មមៃ មេធ្ម ធ្លី មីស្ម រំធី មមើ ធ្មុះ
មមី (រ) ធរណី មហោរី ។

មេធាវីនេះបេះភាសាបី ។ មេអំបៅនោះហើ(រ) រោភ ។ ចៅយីខំថែមេពពៃ ។ ពូឈុំពីសាលំឡមីស្ម ។ មេឃុំសៅហៅមេធ្ម ។

មេរៀនទី ២៨

ជ ឈ

ជ្ម ជោ ជាំ ឈ្ង ជោ ជៀ ជុ ឈា ជិ ឈឺ ជើ ឈ្ម ។
ជឿ ជោះ ជ្ម(រ) ឈា(រ) ជ្ង(រ) ជំងឺ ជីតា រជោ ជីលា
ងេងើ ជរា រជុំ ។

គ្លីជិះដី ។ តាសៅពូកែថៃជំងឺ ។ ចៅខំជឿជីតាភា ។ អាកែជិះសេះញី ។ អាពៅកាឈ (រ) ជីជើលើផៃ ។

មេរៀនទី ២៩

ទ ឆ

ទេ ឆា ទុ ទៃ ទៀ ឆ្ង ទី ទុំ ទាំ ទៅ ឆំ ទូ ឆៅ ទា ។

ទីទៃ នាភិ ទំហំ នាគា ទំនេ (រ) ជាតា ទទា នាទី នគ (រ) ធំ ទំពា នាឡិកា ទេវតា ។

កុំនាំភិទៅទីនោះ ។ តាពៅទៅជាតាអាធាំ ។ អាជាទា (រ) នាឡិកាពីបៅទុំ ។ គេជិះនាភិទៅនគ (រ) ណា ។

## មេរៀនទី ២៦

> ត្រូវយកតួអក្សរដែលសរសេរលើក្រដាសក្រាស់មកបង្ហាញសិស្សមួយៗម្ដង ៗ ហើយសួរសិស្សថាៈ នេះអក្សរអ្វី រួចត្រូវសរសេរតួអក្សរនោះតៗ គ្នាដូចខាងក្រោមនឹងត្រូវហ៊ឹកហ៊ឺនសិស្សឲ្យចេះអាន ចេះសរសេរតួអក្សរទាំងអស់នេះជាប្រាកដ ។

ក ខ គ ឃ ង ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

ប ផ ព ភ ម យ រ ល វ ស

ហ ឡ អ ។

## មេរៀនទី ២៧

ក ខ គ ឃ្ឃ ង្ង ប្ច ឆ្ឆ ជ្ជ ឈ្ឈ ញ ដ្ដ ឋ្ឋ ឌ ឍ្ឍ

ឈ ត ប្ត ទ្ធ ធ្ធ ន្ន ប្ប ផ្ផ ព ភ ម្ម យ្យ ប្រ ល វ្វ
ស្ស ហ ឡ អ ។

មេរៀនទី ២៨

... ... ... ...្យ ... ... ... ... ...្យ ... ... ... ...

ត្យ ... ... ... ... ... ... ...្យ ... ... ... ... ...្យ

្រ... ... ... ...្យ ... ... ។

មេរៀនទី– ២៩

ង៉ ញ៉ ន៉ ប៉ ម៉ យ៉ រ៉ ល៉ វ៉ ហ្វ៉

ង៉ែះ ង៉ោះ ញ៉េះ ញ៉ោះ ញ៉ាំញ៉ើ សេនា ប៉ាឆា តាប៉ែ ប៉ីអុ ម៉ែ ម៉ីផៃ ម្ហូម៉ៅ យ៉ាដាំ រយ៉ៃ បារី ដីរី សាលាបាលី តារ៉ៅ សារ៉ា កាហ្វេ ចៅហ្វា ។

បែម៉ែដើរ (រ) ញ៉ាំញ៉ើ ។ ពូឈុំបេះម្ជូ (រ) បារី ។ តារ៉ៅ

យំពីរោះ ។ គេទៅសាលាបាលី ។ តាប៉ែនេះជូ(វ) ។ បីដៅ៉

ពីសាកាហេូ ។ ចៅម៉ៅបោះខោរយ៉ែទៅជី

មេរៀនទី – ៣០

បិ សិ ហិ អិ

សាបិូ ចៅកែបី ភាសុី ដំហិ (វ) តៅហិូ វាហិូ ហុឺហា ហិ អិូអ (វ) អិូអា អិូអែ អិះអិះ ។

តាបិូបេះគូ (វ) វាហិូ ។ បីអីដើ (វ) ហឺហា ។ អាឡាំបេះសុីតៅហិូ ។ ហិបីជាមេភាសុីដនៅដីហៃ ។ នៅទំនោះគេហិអឺ ។ អាម៉ៅវាទា (វ) សាបិូបីដុំ ។ ឆាវនេះដំរៅពី (វ) ដំហិ (វ) ។

# ឧត្តមដ្ឋាន

## សាលាលីសេ ឬវិទ្យាល័យស៊ីសុវត្ថិ

បើអ្នកទៅតាមផ្លូវ ឌូដារ្ដឺឡាគ្រេ ពីជើងទៅត្បូង អ្នកនឹងឃើញខាងស្ដាំអ្នកទីស្ថានមួយធំទូលាយមានកំពែងលំហោកព័ទ្ធពីមុខ មានផ្ទះខ្ពស់ៗ ធំៗវែងៗ នឹងផ្ទះនៅមុំកំពែងឆ្វេងស្ដាំធំល្មមសង់ពីរជាន់ ស្ថានហ្នឹងហើយដែលហៅសាលាវិទ្យាល័យស៊ីសុវត្ថិ ទីស្ថានហ្នឹងហើយជាសាលាជាន់ខ្ពស់បំផុតនៅស្រុកខ្មែរ ។ ផ្ទះមួយទាបជំបូលដូចក្រចាប់នៅចំ-កណ្ដាលប្រឈមកំពែងមុខជាប៊ុយរ៉ូលោកចាងហ្វាង ។ ផ្ទះធំទាំងអស់មានប្រាំមួយខ្នង នោះផ្ទះបួនសង់ជាវង់ចតុរ័ង្សជុំលានធំទូលាយដែលជាទីសំរាប់លេងសប្បាយនៃសិស្ស ។ ផ្ទះពីរទៀតសង់បន្តគ្នា ពុះក្រឡាបត្តង្សខណ្ឌជាពីរស្មើ ជាទីសយនដ្ឋាននៃសិស្សដែលបានអាហារូបក-រណ៍នាជាន់លើ ។ ជាន់ក្រោមជាទីលល្អ សំរាប់ឲ្យសិស្សជ្រកភ្លៀង ជាភោជនដ្ឋាននឹងជាទីអ៉ានសាលា ។ នៅចុងផ្លូវផ្ទះនេះ សងខាងមានរោងចុងភៅពីខាងជើង នឹងរោងប្រកបការរៀនធ្វើការឈើពីខាងត្បូង ។ ផ្ទះតាមក្បែរវែងបត្តង្សសឹងជាថ្នាក់រៀន ចែកជាសាលាបឋមភូមិជាន់ខ្ពស់មានថ្នាក់ទី ៦ ទី ៥ ទី ៤ នឹងទី ៣ ទីងសាលាមធ្យមសិក្សាទំនើបសំរាប់

ជាតិ ។ ផ្ទះពីរធំល្មមមួយៗ នៅមុំបត្តឹង្ស នោះផ្ទះខាងត្បូងជាលំនៅលោកចាងហ្វាង ផ្ទះមួយទៀតលោកចាងហ្វាងរងជាមួយនឹងលោកអ្នកគ្រប់គ្រងសាលា ។ ផ្ទះពីរខ្នងដែលអមលានរាលទទេ សឹងជាសាលាចែកជាបន្ទប់អប់រំនៃកូនសិស្ស បន្ទប់រៀនគូរ បន្ទប់រៀនគីមី បន្ទប់រៀនសាកពិសោធវត្ថុនូវរូបរាងកាយ នៃមនុស្សនូវសត្វ ក្នុងជាតិផ្សេងៗ នឹងបន្ទប់រៀនភូមិសាស្ត្រ ។

កាលគេឈរមើលពីជាន់លើ គេឃើញលានសាលាវិទ្យាល័យជាសណ្ឋានឧទ្យាន មានស្មៅខៀវស្រងាត់ដូចកំរាលធំហើយនៅគំនូរដោយខ្សែត្រង់ ខ្សែកោង ខ្សែវង់ ខ្សែទាក់ក្រឡាប្រមុះជ្រុងបត្តឹង្សត្រីកោណ គឺផ្កាពណ៌ក្រហមស៊ីគ្នានឹងផ្ទៃស្មៅខៀវ មានគុម្ពផ្កាច្រើនបែបជាគ្រឿងសម្រស់ ក្នុងក្រោងស្រឹងសឹងមានដូងរងត់លេញដំមានស្លឹកចាស់ខ្ចីលេចនឹងផ្ទៃផ្កា គណនាដូចនឹងឧទ្យានជាទីសម្រាន្តនៃអ្នកសិក្សា ដូច្នេះប្អូនអ្នកពាល់គ្នា ខំឲ្យបានមករៀននៅស្ថាននេះ ។

## ពាក្យពន្យល់

វិទ្យា + អាល័យ = វិទ្យាល័យ = ទីលំនៅនៃវិជ្ជា ។ បណ្ណ + អាល័យ =

បណ្ណាល័យ = ទីស្ថិតនៃគម្ពីរ ។ ចតុរង្ស = ចតុរស្រ = បួនជ្រុង ; ចតុង្ស = ដូចគ្នានឹងចតុរង្ស ។

សយនដ្ឋាន = ផ្ទះសម្រាប់ដេក ។ ភោជនដ្ឋាន = កន្លែងសំរាប់បរិភោគ ។ សាលាប្រថមភូមិជាន់ខ្ពស់ = primaire supérieur ។ សាលាមធ្យមសិក្សាទំនើបសំរាប់ជាតិ secondaire moderne national ។ អ្នកគ្រប់គ្រង = économe ។ បន្ទប់អប់រំ = Salle d'études ។ បន្ទប់គីមី = Salle de Chimie ។ បន្ទប់សាកពិសោធ = Salle de sciences d'observation ។ ឧទ្យាន = សួន ។ នន្ទុទ្យាន = សួនព្រះឥន្ទ្រាធិរាជ ។ ស៊ីគ្នា = ធ្វះទល់គ្នា បុប្ផា ឬ បុស្បា = ផ្កា ។ អាហារូបករណ៍ = bourse ។

---

## កីឡា

កីឡាជាល្បែងសម្រាប់កំសាន្តចិត្ត ប៉ុន្តែជាល្បែងកាយពលផង ល្បែងទាំងឡាយនោះមានមកតាំងពីបុរាណ ពីជាន់ណាៗ នឹងកំណត់កាលគ្រាពុំបានផង ។

ល្បែងអាចបន្ទាបន់សេចក្តីអផ្សុក នឹងអាចឲ្យសិទ្ធិកម្មសំរេចប្រ-យោជន៍ដ៏ធំក្នុងការសព្វសារពើទាំងពួង នឹងឲ្យកើតចិត្តបញ្ញាជ្រះថ្លា

ដោយសារកំសាន្ត ព្រមទាំងមានសរីរៈពងកាយមាំពូកែផង ៗ នៅក្នុងកម្ពុជរដ្ឋយើងនេះ កាលសម័យដាន់ប៉ូណាដែលទើបនឹងផុតទៅ ពីរជ្ជ-កាលព្រះបាទស៊ីសុវត្ថិមក មានមនុស្សលឿន មនុស្សរហ័ស មនុស្សខ្លាំងហួសប្រមាណ មនុស្សហ៊ានរង់មុខអាវុធ ខ្លះខ្វែនធ្នូគុនដាវវែង គុនល្បុកតោ គុនដំបង ខ្លះរត់មិនហត់ ខ្លះជ្ញីកខាងសីដក់ សីតែន សីមីលោង ជ្ញីកខាងរាយកូនគោលនឹងកាប់អំពៅ ៗ

ល្បែងកូនគោលជាល្បែងមានសណ្ឋានលាំៗ នឹងល្បែងសព្វថ្ងៃ ប៉ុន្តែគេលេងល្បែងនេះតែវេលាយប់ ៗ នឹងលេងល្បែងនេះ គេតាំងក្រុំបក្សាមិត្រជាពីរពួក ចំនួនតិចច្រើនតាមបាន ឲ្យតែស្មើគ្នា ដោយចំនួនមនុស្ស ៗ អ្នកលេងសឹងកាន់ដំបងប្រវែងមួយព្យាម ហើយដណ្តើមគ្នារាយប្រតាយឲ្យកូនគោលបានមកទីខ្លួន ៗ កូនគោលនោះជាដុំឈើរលួសស្អុតផុតឲ្យឆេះ ជាអើកក្រហមទំហំប៉ុនផ្លែទៀងធំ ៗ ទីដែលលេងជាដីរាបជាបន្ទាត់ ប្រវែងស្រែធំល្មមមួយ ៗ គេចែកទីជាពីរស្មើ តែដាក់កូនគោលត្រង់កណ្តាល ៗ អ្នកលេងតាំងឡាយនោះឈរសងខាងបន្ទាត់រាយគ្នាជាជួរពីស្តាំទៅឆ្វេងតាមបន្ទាត់ ៗ នោះអ្នកដើមទីគឺត្រង់ទីដែលកូនគោលនៅនោះ លើកដំបងប្រុង លុះឮបង្គាប់ថា "ហ៎" គឺរាយប្រតាយគ្នា

ឲ្យកូនគោលតែទៅផ្ទេងពាល់ខ្លួន វាយបញ្ជូនឲ្យគ្នា ពួកម្ខាងដេញដណ្ដើម វាយដីមានស្នូរដំបងតុំៗដែលដាច់ រងើកភ្លើង បែកព្រាយ ៗ បើគោណា ធ្លាយគេវាយយកបាននាំហ្វូងតុងទី ដរាប លាន់ឮសាទរដោយសប្បាយទីងឈ្នះ ៗ

ល្បែងទាំងឡាយបន្ទោបង់សេចក្ដីអផ្សុកទាំងសំណាក់ខ្លួន ប៉ុន្តែត្រូវកុំប្រព្រឹត្តឲ្យហួសប្រមាណ ទាល់តែគេហៅថាអ្នកឆ្កួតល្បែងនោះឡើយ ៗ

## ពាក្យពន្យល់ :–

កីឡា = ល្បែងហាត់ប្រាណ ៗ កាយពល = កំឡាំងខ្លួន ៗ សិទ្ធិកម្ម = សំរេចកិច្ចធ្វើ ៗ ថ្នឹក = ធ្លាប់ ប្រសប់ ៗ ខ្វិន = ថ្នឹកប្រសប់ ៗ បត្យាមិត្ត ឬ បច្ចាមិត្ត = សត្រូវ ៗ គុន = របៀបវាយដោយដំបង ឬ កាប់ដោយដាវតាមក្បូនហាត់ ៗ

គុនល្បុកគោ = អ្នកគុនកាន់កាំបិតពីរ ៗ កាប់អំពៅ = កាប់អំពៅតាំងបាច់តែម្ដង គឺមួយកាំបិតឲ្យដាច់ទាំងអស់ ៗ ឆ្កួតល្បែង = លេងទាល់តែភ្លេចធ្វើរបរកស៊ី ៗ ឆ្កួតមានបី គឺ ឆ្កួតស្រី, ឆ្កួតស្រា, ឆ្កួតល្បែង ៗ

ពាក្យចោទសួរ .–

អ្នកស្គាល់ល្បែងអ្វីខ្លះ ? ក្នុងសាលាគេបង្ហាត់ល្បែងអ្វី ? ល្បែងឲ្យគុណដូចម្ដេច ? ល្បែងឲ្យទោសដូចម្ដេច ? បៀ, អាកៀន ជាល្បែងដែរឬអ្វី ? ល្បែងទាំងនេះត្រូវកាន់យក ឬ ត្រូវវៀរចាក ? ហេតុអ្វី ? ។

---

## មជ្ឈមដ្ឋានទី ២

## សាលាបឋមសិក្សាសព្វថ្ងៃ

ការសិក្សាជាន់មុនផ្លាស់ប្ដូរបែបភាពរបៀបបាត់អស់ទៅហើយ គេលែងទាំងនឹកឃើញថាជាយ៉ាងដូចម្ដេចផង ។ ក្នុងរបៀបសិក្សាជាន់ដើម សិស្សទៅរៀនឥតស្ថិតស្ថេរទេ នៅវត្តនឹងបង្រៀននោះគ្រូអង្គុយឬទ្រោលលើកំពលក្ដារ បង្រៀនបង្ខំណាស់ ដោយឲ្យទន្ទេញតែមាត់ អក្សរពីរបីតួក្នុងមួយពេល ៗ ។ ឥឡូវនេះ រហូតដល់ភូមិដាច់ដោច គេឃើញសាលារៀនដ៏មានបន្ទប់ទូលាយភ្លឺស្រឡះ មានខ្យល់ចេញចូលពេញលេញ ហើយមានឱកាសយ៉ាងក្សេមក្សាន្ត ទៅលើវាលស្រែដែលមានច្រាំងទ្រាយលាំៗគ្នា ឬទៅលើភូមិដែលមានផ្ទះសុទ្ធតែស្ទឹកប្រឡាំ ៗ នឹង

ពណ៌ដី ៗ សឹងប្រកបដោយរបៀបរៀបចំត្រឹមត្រូវល្អ សាលាបឋមសិក្សាមានឧបករណ៍សំរាប់ការរៀន គឺ សៀវភៅស្វាធ្យាយន៍ ផ្ទាំងគំនូរផែនទី ផ្ទាំងគំនូររូបសំរាប់ព្យួរ មានវត្ថុសំរាប់ជាតឹកតាងរៀបរៀងដោយឡែក គឺសិលាជាតិ លោហជាតិ គ្រាប់រុក្ខជាតិ សាច់ឈើ ស្បែកកំណាត់សម្ពត់ល្អ ៗ ហើយមានតទៅទៀត ប្រដាប់ធ្វើស្រែចំការដ៏មានទ្រង់ទ្រាយមែន ៗ តូច ៗ ដែលសិស្សធ្វើនឹងខ្លួនឯង ៗ

ឯរបៀបរៀនក្រសោបចំណេះទាំងអស់សំរាប់ប្រឋមវិជ្ជា គឺធម្មក្រឹត្យភាសាបាក្យត្រ ឬពង្សាវតារ ភូមិសាស្ត្រនព្វន្ត វិជ្ជាសាស្ត្រដ៏ជាចំណេះប្រក្រតី ៗ មិនតែប៉ុណ្ណោះមានរៀនគូរគំនូរ រៀនការហត្ថកម្ម នឹងហាត់ពលវិធីទៀតផង ៗ ទោះជាក្នុងខ្នង់តាពង់ បែកពេលរៀនញ៉ាកស្អុកក៏ដោយ ការរៀនសូត្រទៅជាការឲ្យកើតជម្រេក ព្រោះគ្រូបេះញ៉ាំងសិស្សឲ្យត្រេកអរឲ្យក្លាហាន ហើយបង្រៀនតែល្មមតាមកម្លាំងក្មេង ៗ ជួនគ្រូនាំសិស្សទៅបង្រៀនក្នុងពេលដើរលេងក៏មាន គឺឲ្យមើលគេភ្ជួរស្រែគេច្រូតស្រូវ គេលក់ដូរនៅផ្សារ មើលស្ពានីយ មើលប្រៃសណីយ ស្ពានដែលនៅជិត ៗ ៗ

## ពន្យល់ពាក្យ

ឱកាស = ទីនេះសំដៅត្រង់ការមើលទៅឃើញជុំវិញ ហើយក្សេមក្សាន្តក្នុងចិត្ត ។

ឧបករណ៍ = គ្រឿងប្រដាប់សំរាប់បង្រៀន ។ ពលវិធី = ការហាត់ប្រាណឲ្យមានកម្លាំង ។

ស្ថានីយ = ដំណាក់រទេះភ្លើង ។ ប្រៃសណីយ = ប៉ុស្តិ៍ខ្សែលួស ។

---

# មជ្ឈិមដ្ឋាន ទី ១

**រៀនមើល - សរសេរតាមសូត្រ**

## រឿងវាយឆ្កែខុស

មានសេដ្ឋីម្នាក់ មានឃ្លាំងមាស ឃ្លាំងប្រាក់ច្រើនណាស់ ហើយចិញ្ចឹមឆ្កែកាចប្រាំ ដើម្បីឲ្យនៅចាំរក្សាឃ្លាំងមាសប្រាក់នោះ ។ សម័យថ្ងៃមួយ មានចោរបួននាក់ជីកទម្លុះរូងដីពីក្រៅរបង ហើយចូលតាមរូងនោះទៅដល់កណ្ដាលឃ្លាំងមាសឃ្លាំងប្រាក់ ។ ឆ្កែទាំងប្រាំធុំក្លិនមនុស្ស

ក៏នាំគ្នាពចូលទៅទាំងចោរក្នុងរូងនោះស្លាប់អស់ទៅ ។ ឯគំនរមាសប្រាក់ ក៏បាក់ស្រុតទៅគ្របលើរូង ។ សេដ្ឋីចូលទៅត្រួតត្រាមើលឃ្លាំងឃើញ បាក់ស្រកស្រុតខុសប្រក្រតីដូច្នោះ ក៏ខឹងទឹងនឹងឆ្កែ ហើយបង្គាប់កូនក្មួយឲ្យយកឆ្កែទៅសម្លាប់អស់ទៅ ។ លុះដល់ថ្ងៃក្រោយ បាន ឃើញខ្មោចអាចោរ ទើបសេដ្ឋីទឹកស្ដាយស្រណោះឆ្កែទាំងអស់នោះណាស់ ហើយមានវិប្បដិសារីថា : “ អញវាយឆ្កែខុស ” ។

## ពន្យល់ពាក្យ.–

សេដ្ឋី (ម.ថ. សេតឋី) = អ្នកមានទ្រព្យឧត្តម, អ្នកមានទ្រព្យច្រើន អ្នកមានធំ ។ ឃ្លាំង= ផ្ទះសម្រាប់ទុកដាក់ទ្រព្យរបស់ ។ ឧមង្គ (អ.ថ. អ៊ុម ម៉ង់ ឬតាមទម្លាប់ថា អ៊ុម មុ៉ង ) = រូងដែលជីកលុងក្នុងដីឬក្នុងភ្នំ ជាផ្លូវដើរបាន ។ ខុសប្រក្រតី= មិនដូចធម្មតា ។ កូនក្មួយ=មនុស្សនៅក្នុងបន្ទុក[illegible]ចៅហ្វាយនាយ ។ វិប្បដិសារី ម.ថ. វិបប៉ៈដិសារី)= មានសេចក្ដីក្ដៅក្រហាយ, សេចក្ដីទឹកស្ដាយក្រោយ ។

ពាក្យសួរ – មនុស្សដូចម្ដេចដែលហៅថាសេដ្ឋី ?

សេដ្ឋីនោះចិញ្ចឹមឆ្កែប៉ុន្មាន ? ឆ្កែនោះកាចឬស្លូត, ? ចិញ្ចឹម

ទុកដើម្បីអ្វី ? ហេតុម្ដេចបានជាសេដ្ឋីឲ្យសម្លាប់ឆ្កែចោល ? ដល់ក្រោយមកសេដ្ឋីមានវិប្បដិសារីថាដូចម្ដេច ? ព្រោះអ្វី ? ។

# វាចិកដ្ឋាន

## បង្រៀនពាក្យនិងភាសា

ពាក្យនិងភាសា គឺជាវិជ្ជាមួយយ៉ាងវិសេស ដែលបំបែកទៅវិជ្ជាឯទៀត ដូចជាបង្រៀនមើល-សរសេរតាមសូត្រ ។ល។

ឯនឹងបង្រៀនពាក្យ, មុនដំបូងត្រូវបង្រៀនពាក្យណាដែលងាយ ៗ សិន រួចសឹមពាក្យពិបាកជាខាងក្រោយ ។

បើបង្រៀន នាម ត្រូវមានរបស់ដែលជា នាម មកបង្ហាញពន្យល់ បើគ្មានរបស់នោះទេ ត្រូវគូររូបបង្ហាញសិស្ស បើមានរូបភាពស្រាប់ ត្រូវចង្អុលបង្ហាញផង ។

បង្រៀន គុណនាម ត្រូវប្រៀបប្រដូចរបស់នោះ ឲ្យឃើញថាតូចឬធំ សឬខ្មៅ ល្អឬអាក្រក់ ។ល។

បង្រៀន កិរិយាសព្ទ គឺត្រូវឲ្យសិស្សធ្វើទំនងតាម កិរិយារបស់នោះ គឺដូចជាបង្គាប់សិស្សឲ្យក្រោក ឲ្យឈរ ឲ្យដើរ ឲ្យផ្ទូត ឲ្យបិត្ត ។ល។

# អាទិត្យទី១._ បង្រៀនពាក្យ

## ១ _ អំពីសាលារៀន

នាម -សាលារៀន ឆ្នាំសិក្សា សិស្ស ពេលចូលរៀន ពេលសំរាក សាលាសិក្សាវត្ត សាលាបឋមវិជ្ជានៅភូមិ សាលាបំពេញវិជ្ជា សា-លាឧត្តមវិជ្ជា សញ្ញាប័ត្រ ។

គុណនាម = ថ្មី ចាស់ ល្អ អាក្រក់ ខ្ពស់ ទាប យូរ ឆាប់ ជិត ឆ្ងាយ ខ្ជិល ឧស្សាហ៍ ។

កិរិយាសព្ទ = សុំចុះឈ្មោះ ចូលរៀន រៀនបំពេញវិជ្ជា ឈប់សំ-រាក ឈប់រៀន ឡើងថ្នាក់ ប្រឡង បានសញ្ញាប័ត្រ ។

ហាត់ភាសា- ក្នុងមួយឆ្នាំសិក្សា សិស្សរៀនប៉ុន្មានខែ ? ឈប់សំរាកប៉ុន្មានខែ ? នៅពេលណាដែលសិស្សចូលរៀនជាថ្មី ? សាលាដែលអ្នករៀនឈ្មោះសាលាអ្វី ? (សាលាសិក្សាវត្តឬសាលាបឋម-វិជ្ជានៅភូមិ ។ល។ ) សិស្សត្រូវធ្វើដូចម្តេចដើម្បីឲ្យបានឡើងថ្នាក់ ? ឲ្យបានប្រឡងជាប់ ? សិស្សកំជិលបានសម្រេចប្រយោជន៍អ្វីដែរឬទេ?

វិធីហាត់សរសេរ -- ឲ្យតែងសេចក្តីជាឃ្លា ឬ ឲ្យបំពេញសេចក្តីនៅកន្លែងចន្លោះពង្រី ដូចខាងក្រោយនេះ ៖

ក្នុងមួយឆ្នាំសិក្សា ... (សិស្ស) មករៀន ... (៩ខែ) ឈប់សំរាក ... (៣ខែ) ។ ខ្ញុំរៀននៅសាលា ... (សិក្សាវត្តឬសាលាបឋមវិជ្ជានៅភូមិ ។ល។) ។ ខ្ញុំត្រូវ ... (ខំស្វាហាប់រៀនសូត្រ) ដើម្បីឲ្យបានឡើងថ្នាក់ប្រឡងជាប់នៅ ... (ពេលដាច់ឆ្នាំ ។

## ២-សិស្សឧស្សាហ៍រៀនសូត្រ

សៀវភៅវិជ្ជាខេមរភាសាបរិច្ឆណដ្ឋានទំព័រ ២៥ ។

កែតម្រូវពាក្យក្នុងមេរៀននេះ៖ គឹត=សរសេរជាគិត ។ មឹន=ជាមិន ។ ត្រិម = ជាត្រឹម ។

សុំឲ្យរើសពាក្យ = នាម - គុណនាម - កិរិយាសព្ទ ដែលមានក្នុងមេរៀននេះ ដាក់ឲ្យសិស្សរៀនផង “

ហាត់ភាសា = អ្នកត្រូវធ្វើដូចម្តេចដើម្បីឲ្យបានចេះដឹង ? អ្នកស្រឡាញ់បំណេះវិជ្ជាឬទេ ? ព្រោះអ្វី ? មនុស្សចេះដឹងយ៉ាងដូចម្តេច ? ចុះមនុស្សល្ងង់ខ្លៅយ៉ាងណាវិញ ? ដល់អ្នកធំឡើងអ្នកចង់ធ្វើអ្វី ? (ចង់ធ្វើនាម៉ឺន ឬ ចង់រកស៊ី) ។ ហេតុអ្វី ? ។

# បង្រៀនមើល

## ១– ពីព្រោះអ្វីបានជាខ្ញុំទៅសាលារៀន

*សៀវភៅវិជ្ជាខេមរភាសាបរិច្ឆេទណាថ្នាក់ ទំព័រ ៤ មេរៀនទី ៣ ។*

ពាក្យពន្យល់ .–

*មិត្តសំឡាញ់ – ពុំគមាន – ផលព្រះធរណី – ទុន្ទាន – លុះដោយតន្ទ័ធម៌ ។*

## ២– សេចក្ដីព្យាយាមនឹងបានសំរេចដូចប្រាថ្នា

*សៀវភៅវិជ្ជាខេមរភាសាអាទិកថ្នាក់ ទំព័រ ៨២ មេរៀនទី ៥៥ ។*

ពាក្យពន្យល់ .–

*សញ្ញាប័ត្រឧត្ដមវិជ្ជា – សាលាបឋមវិជ្ជាបាក់ទី-ខ្មែរ – ដុតបំភ្លឺរៀន – សេចក្ដីព្យាយាម ។*

## របៀបបង្រៀនមើល

*ឲ្យបម្ងន់សូត្រនេះនៅក្នុងថ្នាក់ដោយផ្ចិតផ្ចង់ បើជាសិស្សគ្មានសៀវភៅគ្រប់គ្រាន់ទេ ។*

គ្រូត្រូវមើលពាក្យនេះឲ្យសិស្សស្តាប់ ជាមួយ ៗ ឲ្យច្បាស់ពាក្យ ឬ តួអក្សរនោះ ។

គ្រូមើលសូត្រនេះឲ្យសិស្សថាតាមពីរ ឬ បីនាក់ម្តង ឬឲ្យថាតាមព្រមគ្នាទាំងអស់ក៏បាន រួចបង្គាប់ឲ្យសិស្សម្នាក់មើលឲ្យថា ខ្សល់អក្សរឲ្យត្រឹមត្រូវ ។

ពន្យល់ពាក្យពិបាកដែលនៅក្នុងសូត្រ ។

ហៅសិស្សផ្លាស់គ្នាឲ្យមើលសូត្រនេះ កុំហៅសិស្សរៀងគ្នាតាមតុ

គ្រូបង្គាប់ឲ្យកែពាក្យសំដីណាដែលសិស្សថាមិនច្បាស់ ។

## សរសេរតាមសូត្រ

សូមលោកគ្រូជ្រើសរើសសេចក្តីណាដែលបានបង្រៀន ក្នុងវិធីបង្រៀនពាក្យ ហាត់ភាសា បង្រៀនមើល យកមកបង្រៀនដាក់អក្សរត្រឹមត្រូវផងចុះ តែមិនត្រូវយកពាក្យពិបាកណាមួយ ដែលសិស្សមិនបានឃើញ បានស្គាល់មកឲ្យសរសេរតាមគ្រូថានោះទេ ។

# អំពីបង្រៀនដាក់អក្សរត្រឹមត្រូវតាមគ្រូហា

មុនដំបូងគ្រូត្រូវមើលសូត្រឲ្យសិស្សស្ដាប់ រួចសរសេរពាក្យពិបាកផា ចំណាំនៅក្ដារខៀន ហើយពន្យល់ពាក្យនោះផង ។

ឲ្យសិស្សសរសេរពាក្យនោះនៅលើក្ដារខៀនជាច្រើនដងហើយឲ្យមើលប្រកបពាក្យនោះ រួចហើយលុបចេញ ។

គ្រូលុបពាក្យដែលសរសេរនៅក្ដារខៀនចោលចេញ ធ្វើបែបនេះដើម្បីឲ្យសិស្សឃើញពាក្យនោះត្រឹមត្រូវ ៖

ក)– ឲ្យសិស្សចំណាំដោយភ្នែកបានឃើញ ។

ខ) - ឲ្យសិស្សសរសេរពាក្យនោះច្រើនដង ដើម្បីឲ្យចំណាំដោយដៃបានគូស - បានសរសេរ ។

ហៅសូត្រឲ្យសិស្សសរសេរតាម ជាឲ្យមួយ ៗ ហើយច្បាស់លាស់ផង គ្រូដើរក្រោយខ្នងសិស្ស ដើម្បីសំគាល់មើល ថា សិស្សនេះសរសេរខុសច្រើន សិស្សនោះសរសេរត្រូវច្រើន ។

គ្រូសរសេរកែសូត្រនេះនៅក្ដារខៀនម្ដងមួយឃ្លា ៗ ឲ្យសិស្សកែសៀវភៅវាតាម ពាក្យណាដែលសរសេរខុសឲ្យវាគូសខ្មៅដៃពីក្រោម ឲ្យសរសេរពាក្យត្រូវពីលើពាក្យខុសហើយដាក់ចំនួនខុសប៉ុន្មានៗ ផង ។

គ្រូត្រូវត្រួតមើលជាកតិទុកឲ្យសិស្សផង ។

ឲ្យសិស្សសរសេរពាក្យដែលខុស ( ខុសមួយមាត់ឲ្យសរសេរមួយ បន្ទាត់ ) ។

## អក្សរផ្ចង់

យើងត្រូវជ្រើសរើសរកតួអក្សរដែលមានសណ្ឋានប្រហែល ៗ គ្នា មកដាកឲ្យសិស្សហាត់សរសេរ ដូចខាងក្រោមនេះ ៖

ក ភ គ ត ឥ ឦ

ក កា កី កូ កួ កើ កេ កៃ កោ កុំ កំ កាំ

កកេរ កកូរ កុំកិកកុក កើតក្ដី កាំភ្លើង ភ្លាត់កៃ ភិតភ័យ កុំភូតភរគេ ត្រីកំភ្លាញ

(ឲ្យសរសេរអក្សរធំ ១ បន្ទាត់ កណ្ដាល ១ បន្ទាត់ តូច ១ បន្ទាត់)

សូមធ្វើឲ្យសព្វគ្រប់តាមរបៀបបង្រៀនអក្សរផ្ចង់ ។

# កុមារដ្ឋាន

## រៀនពាក្យនិងភាសា

### អាទិត្យទី ១._ វត្ថុនៅក្នុងថ្នាក់រៀន

ពាក្យ.– ដីស, ក្តារឆ្នួន, ខ្មៅ, ដងប៉ាកកា, ទឹកខ្មៅ, ក្តារខៀនគំនូរ, កំណាត់សំពត់, បន្ទាត់វែង, ផែនទី, ផ្ទាំងគំនូរ, ផ្ទាំងច្បាប់អក្សរ ៗ តារាងប្រក្រតិទិន, តារាងកំណត់ពេលរៀន, ផ្ទាំងរបៀបរៀនតាមខែ ៗ

ដីសស, ក្តារឆ្នួនខ្មៅ, ខ្មៅដៃស្រួយ, ដងប៉ាកកាមូល, ៗ ធំ តូច, គគ្រាត, កខ្វក់, រយ៉ៃ, ត្រង់ សំប៉ែត, ស្រស់, ល្អ, ខៀវ, ខ្មៅ, ក្រហម, ចុងស្រួចស្មើ, ចុងស្រួចវែង, ច្បាស់, ស្រអាប់, ៗ

សរសេរអក្សរ, លុបក្តារ, ចិតខ្មៅដៃ ៗ ព្យួរ, បញ្ឈរ, ភ្ជាប់, លុប, សរសេរ, ចង្អុល, មើល, គូរ, គូស, លើកដាក់, ៗ

ភាសា.– អ្នកណាឬនរណាមានខ្មៅដៃ? មានដងប៉ាកកា? អ្នកមានដីសឬទេ? ដីសរបស់អ្នកមានសភាពដូចម្តេច? ក្តារឆ្នួននេះជារបស់អ្នកណា? បន្ទប់រៀនអ្នកមានពណ៌យ៉ាងដូចម្តេច? នៅក្នុងបន្ទប់រៀននោះមានវត្ថុអ្វីខ្លះ?

អាទិត្យទី ២.-

ពាក្យ.- តុកូនសិស្ស, តុគ្រូ, ជើងម៉ា, កៅអី, ថតតុ, ជើងតុ, ទូ, កញ្ចក់ទូ, អំបោស, បង្កៀង, ជូត ៗ វែង, រលោង, រលើប, រៀប, ត្រង់, ចាស់, រលុង, ផុយ, ក្លឹ, រេប, ខូច ៗ ហូត, ដក, រៀប, ជូត, ផុស, សំអាត, បោស, ប្រយ័ត្ន, ទុក ៗ

អាទិត្យទី ៣.-

ពាក្យ .- សៀវភៅសរសេរ, សៀវភៅនព្វន្ត, សៀវភៅវត្តស្វាធ្យាយន៍, សៀវភៅភូមិសាស្ត្រ, វចនានុក្រម, សៀវភៅកម្ពុជាវតារ, ក្រដាស, ក្រដាសផ្តិត, ជ័រលុប, បន្ទាត់, ស្វាបប៉ាកកា, ក្របសៀវភៅ ៗ

ស្តើង, ក្រាស់, ថ្មី, ចាស់ ទក់, រហែក, ទន់, រឹង, ក្ដិច្ចៈ, ដាម, ស្រួច, រឹល ៗ ដាក់ក្រប, អានពាក្យ, ទន្ទេញ, បើកសៀវភៅ, គូសបន្ទាត់, លប់, ផុស, សូត្រ, ស្វាធ្យាយ, ផ្តិតទឹកខ្មៅ ៗ

## រៀនមើលសរសេរ

អាទិត្យទី ១.-

ថ្ងៃទី ១.- ឲ្យសរសេរ "អ" ហើយថា អ ៗ គូរផងថាផង

ហើយគ្រូឱ្យថាពាក្យបណ្ដុះស្មារតី "ខ្ញុំអរ" "បាយអ" "ប៉ុអ" "អុក" ។

ថ្ងៃទី ២.– "អា" - ពាក្យបណ្ដុះស្មារតី "អារឈើ" "អាទេះ"

ថ្ងៃទី ៣.– អិ, អី, អឹ, អឺ – ពាក្យបណ្ដុះស្មារតី "អើកបាយ" "អីអើ" ។

ថ្ងៃទី ៤.– អុ, អូ, អួ, ឱ្យរកពាក្យបណ្ដុះស្មារតី ។

ថ្ងៃទី ៥.– អ, អា, អិ, អី, អឹ, អឺ, អុ, អូ, អួ, ។

ដម្បូន្មាន .– នៅថ្នាក់កុមារដ្ឋានគ្រូបង្ខំឱ្យក្មេងចាំដៃតែប៉ុណ្ណោះបានហើយ ។

## អាទិត្យទី ២.–

អេ, អើ, អឿ, អៀ, អែ, អៃ, អៅ, អោ, អាំ, អុំ, អះ, អំ

## អាទិត្យទី ៣.–

អាទិត្យនេះគ្រូបង្រៀននៅថ្ងៃដំបូង "ក" ។ ពាក្យបណ្ដុះស្មារតី កកុក, កដប, កករទឹក, ទឹកកក, កដៃ, កជើង, ។

ថ្ងៃទី ២.– ជាលំដាប់តទៅ = កា, កិ, កី, កឹ, កឺ, កុ, កូ, កួ, កើ, កេ, កៀ, កឿ, កែ, កៃ, កោ; កៅ, កំ, កុំ, កាំ, កះ, ។ រៀនប្រកប = កក កុក, កែក, កាក, កោក, កេក, កុះ, កោះ ។

---

# បរិទដ្ឋណាផ្ទាន

## រៀនពាក្យនឹងភាសា

### អាទិត្យទី ១ នឹងទី ២.–

សូមបង្រៀនសាពីពាក្យដែលបានរៀនទាំងអម្បាលម៉ាននៅកុមារដ្ឋានក្នុង ខែកញ្ញានេះ ។

### អាទិត្យទី៣ នឹង ទី ៤.–

សូមសាបង្រៀនឡើងវិញពាក្យដែលបានរៀនពីអាទិត្យមុនៗមក ។

## រៀនមើល

### អាទិត្យទី ១ នឹងទី ២ –

១ .– កូនសិស្សទុសព្វាហ៍រៀនសូត្រ (សៀវភៅបរិ. ទំព័រ ២៥)

២.– កូនសិស្សខ្ជិល (សៀវភៅដែលទំព័រ ២៦)

៣.– ត្រូវតែរៀនដំរិះវិជ្ជា (សៀវភៅដែលទំព័រ ៦១)

សុំឲ្យកែពាក្យខុស .– សូត្តជាសូត្រ; គឹតជាគិត; មឹនជាមិន; ត្រិមជាត្រឹម; (ទំព័រ ២៥); ខ្ជឹលជាខ្ជិល; កិរិយ៉ា ជាកិរិយា (ទំព័រ២៦) ។

អាទិត្យទី៣នឹងទី៤ .–

១ – ជម្ងឺកមរមាស់ សៀវភៅដែលទំព័រ ២២ ទៅ ២៣)

២ – ជម្ងឺកមរមាស់ (ត) (ទំព័រ ២៤-២៥)

៣ – ត្រូវថែទាំសំលៀកបំពាក់ (សៀវភៅដែលទំព័ ៧៦ )

## សរសេរតាមសូត្រ

១ – កូនសិស្សឧស្សាហ៍រៀនសូត្រ (ក្នុងមេរៀនមើល)

២ កូនសិស្សខ្ជិល (សៀវភៅដែល ទំព័រ ២៦ ដល់រឿយៗ) ។

៣ កូនសិស្សខ្ជិល (ត) ដល់ចប់ ។

# មធ្យមដ្ឋានទី២ និង ឧត្តមដ្ឋាន

## នព្វន្ត

### អាទិត្យទី ២.– អំពីរៀនរាប់នឹងមើលបំនួន

សូមលោកគ្រូបង្ហាត់មើលនឹងសរសេរចំនួនលេខ១ ដប់ ដំបូងផងចុះ ព្រោះសុទ្ធតែធ្លាប់ប្រសប់ស្រាប់ហើយ ។

១ ដប់ដងត្រូវជាដប់ (១០) គេសរសេរលេខ ១ ហើយថែមសូន្យមួយខាងស្តាំ ។

១០ ដប់ដង ត្រូវជាមួយរយ (១០០) ។

ពីដប់ទៅ ១០០ គេត្រូវរាប់ថា:

ដប់... ១០ ហុកសិប ៦០

ម្ភៃ... ២០ ប៉ែតសិប ៨០

. . . . . . . . . . . . .

មួយរយ ... ១០០ ។

ទី៥ រាប់ចំនួនពី ១០ ដល់ ១០០ គេត្រូវថែមចំនួនរាយតាំង៩ ទៅលើខ្ទង់ដប់ ៗ

គេរាប់ថាដប់មួយ ១១ ឬមួយដណ្ដប់

- ដប់ប្រាំពីរ ១៧ ឬប្រាំពីរដណ្ដប់
- ម្ភៃប្រាំបួន ២៩
- ហាសិបបួន ៥៤
- កៅសិបប្រាំបួន ៩៩ (ល) ៗ

៦ ចំនួនពី ១០០ ដល់ ១.០០០ គេត្រូវថែមចំនួនពី ១ ដល់ ៩៩ ទៅលើចំនួនរយគឺ:

មួយរយមួយ ១០១

មួយរយប្រាំបី ១០៨

ពីររយចិតសិបប្រាំបួន ២៧៩

ប្រាំពីររយប៉ែតសិបបួន ៧៨៤

. . . . . . . . . . . .

ប្រាំបួនរយកៅសិបប្រាំបួន ៩៩៩ ៗ

រៀនសរសេរចំនួន ៗ

ក) ពី ១០ ដល់១០០ ។ ត្រូវសរសេរខ្ទង់ដប់មុនរួចសរសេរខ្ទង់រាយដាក់ខាងស្តាំទៀត ។

ឧទាហរណ៍– ដប់ប្រាំពីរ ១៧ ចិតសិបប្រាំបួន ៧៩ កៅសិបប្រាំបួន ៩៩ (ល) ។

ខ) ចំនួនពី ១០០ ដល់ ១.០០០ ត្រូវសរសេរខ្ទង់រយមុនរួចសរសេរខ្ទង់ដប់ខ្ទង់រាយដាក់តៗ ខាងស្តាំទៀត ។ ឯខ្ទង់ណាគ្មានលេខគេដាក់សូន្យជំនួស ។

ដូចជា មួយរយសាមសិបប្រាំពីរ (១៣៧) គេសរសេរលេខ១ខ្ទង់រយមុន រួចសរសេរខ្ទង់ដប់គឺលេខ ៣ ដាក់ខាងស្តាំ រួចហើយសរសេរលេខ ៧ ខ្ទង់រាយដាក់តមកទៀតបានជា ១៣៧ ។

ពីររយប្រាំបួន ២០៩

ប្រាំរយ ៥០០ (ល) ។

ត្រូវកុំភ្លេចដាក់សូន្យនៅខ្ទង់ណាដែលគ្មានលេខ ។

ការហាត់គិតមាត់ទទេ.– អំពីគុណចំនួននឹង ១១ ។

នឹងគុណចំនួនតាំងពី ២ ខ្ទង់នឹង ១១ នោះត្រូវបូកលេខក្នុងចំនួន

តាំងនោះ បើឃើញចំនួនសារុបមិនហួស ពី ៩ ទេ ត្រូវចុះចំនួនសារុបដែលបូកបាននោះចំចន្លោះកណ្ដាលលេខតាំងដូចខាងក្រោមនេះ ៖

ឧបមា ៣៥ × ១១=

ត្រូវគិតថាកងចំនួន ៣៥ មានលេខ ៣ មួយគួ និងលេខ ៥ មួយគួ ត្រូវផ្សំ ៣ និង ៥ ត្រូវជា ៨ យកលេខ ៨ ទៅចុះចំចន្លោះកណ្ដាលចំនួន ៣៥ ទៅជា ៣៨៥ ដូច្នេះ ។

ម្យ៉ាងទៀតបើបូកទៅហើយឃើញចំនួនសារុបលើសពី ៩ ឡើងទៅ ត្រូវចុះតែចំនួនកាយទៅចំចន្លោះកណ្ដាលចំនួនតាំង ហើយយកលេខខ្ទង់ ១០ ទៅថែមលើខ្ទង់ដប់ដូចខាងក្រោមនេះ ៖

៦៧ រៀល × ១១ = ៧៣៧ ព្រោះ ៦ និង ៧ ត្រូវជា ១៣ ។

ឲ្យសិស្សហាត់គិតលេខខាងក្រោមនេះ ៖

| | |
|---|---|
| ៣៦ × ១១ = | ៧៥ × ១១ = |
| ៥៥ × ១១ = | ៩២ × ១១ = |
| ៣២ × ១១ = | ៧៨ × ១១ = |

**អំពីលេខបូក.—** ឧបមា ឪពុកខ្ញុំបេះបានស្វាយមួយកញ្ជើ បើខ្ញុំចង់ដឹងចំនួនស្វាយរបស់ឪពុកខ្ញុំក្នុងកញ្ជើនោះតើមានប៉ុន្មាន នោះខ្ញុំត្រូវ

រាប់ផ្លែស្វាយក្នុងកញ្ចើនោះទាំងអស់ ខ្ញុំឃើញថាក្នុងកញ្ចើនោះមានផ្លែស្វាយ៦៧ ។

បើខ្ញុំបេះស្វាយបានមួយកញ្ចើទៀត ហើយខ្ញុំចង់ដឹងចំនួនស្វាយក្នុងកញ្ចើទី ២ នេះ ខ្ញុំក៏ត្រូវរាប់ដូចខាងលើនេះដែរ ខ្ញុំឃើញមានចំនួនស្វាយ ១៥ ។

ឥឡូវនេះ បើខ្ញុំចង់ដឹងចំនួនផ្លែស្វាយដែលខ្ញុំបានបេះទាំង ២ កញ្ចើនោះតើមានប៉ុន្មានទាំងអស់ ? នោះខ្ញុំមិនបាច់យកស្វាយទាំងពីរកញ្ចើមកចាក់ដាក់បញ្ចូលគ្នាជាគំនរតែមួយ ហើយរាប់សាជាថ្មីទៀតនោះទេ ខ្ញុំគ្រាន់តែធ្វើលេខបូកក៏អាចដឹងចំនួនផ្លែស្វាយទាំងពីរកញ្ចើបាន គឺយកចំនួនស្វាយ ៦៧ ក្នុងមួយកញ្ចើទី ១ មករួមនឹងចំនួនស្វាយ ១៥ ក្នុងកញ្ចើទី ២ ។

នឹងបូកចំនួនគេសរសេរដូច្នេះ

ស្វាយ ៦៧ + ស្វាយ ១៥ = ៨២ ។

នឹងធ្វើលេខបូកគេត្រូវតាំងចំនួន មួយលើមួយក្រោមត ៗ គ្នា

ដាក់លេខឲ្យចំខ្ទង់ គឺខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់រយក្រោមខ្ទង់រយ ខ្ទង់ដប់ក្រោមខ្ទង់ដប់ដូចខាងក្រោមនេះ ។

$$
\begin{array}{r} ៦៧ \\ +\ ១៥ \\ \hline ៨២ \end{array}
$$

**ការហាត់**.– សូមឲ្យសិស្សធ្វើលេខឲ្យបានច្រើននៅក្ដារខៀន ។

១៣៦ + ៣១៥ + ២០៧ = ៥២៣ + ៧៥ + ១៣៣ =

៣១៥ + ៦៣៦ + ២៤៣ = ៣៥១ + ១០៣ + ១៧ =

**បំណោទ**.– សណ្ដែកបាយបីបាវ បាវទី ១ ទម្ងន់ ១០៨ គីឡូក្រាម បាវទី ២ ទម្ងន់ ៩៨ គីឡូ បាវទី ៣ ទម្ងន់ ១១៣ គីឡូ ឯបាវ ៥ ទៀត បាវនិមួយ ៗ ទម្ងន់ស្មើនឹងបាវទី ៣ ។ តើសណ្ដែកទាំងអស់មានទម្ងន់ប៉ុន្មានគីឡូក្រាម ។

## អាទិត្យទី ២.–

មើលនឹងរាប់ចំនួនលើសពី ១.០០០ ឡើងទៅ ។

មួយពាន់ដប់ដងត្រូវជាមួយម៉ឺន . . . ១០.០០០

មួយម៉ឺន ១០ ដងត្រូវជាមួយសែន . . ១០០.០០០ ។ល។ នឹងសរ-

សេរចំនួនពី ១.០០០ ឡើងទៅត្រូវថែមលេខចំនួនពី ១ ដល់ ៩៩៩ ទៅ លើខ្ទង់ពាន់ឬខ្ទង់ម៉ឺន

ដូចជា បួនពាន់ពីរ .......... ៤០០២

ប្រាំបីពាន់ម្ភៃបី ............ ៨០២៣

ពីរពាន់ប្រាំបួនរយកៅសិបប្រាំបួន .... ២៩៩៩

ត្រូវសរសេរខ្ទង់ពាន់ឬលេខខ្ទង់ម៉ឺនមុន ទើបចុះខ្ទង់ពាន់ឬខ្ទង់រយ ខ្ទង់ដប់នឹងខ្ទង់ឯកត ។ ទៅខាងស្តាំទៀត ។ ខ្ទង់ណាដែលគ្មានលេខ ត្រូវដាក់សូន្យជំនួស ។

៣៧០៤ ; ៩០០៥ ; ១៣៥០៩ ។ ល ។

## វិធីរកខុសត្រូវលេខបូក

បើចង់ដឹងថាលេខបូកនីមួយ ៗ ខុសឬត្រូវ គេត្រូវបូកសាជាថ្មីម្ដងទៀត ពីក្រោមឡើងទៅលើវិញដូចខាងក្រោមនេះ ។

| | |
|---|---|
| ៣៩៧ | ៥៨២ |
| ៥៨ | ៣៩៧ |
| ១២៧ | ៥៨ |
| ៥៨២ | ១២៧ |

បើឃើញចំនួនសរុបត្រូវគ្នា លេខបូកនោះត្រូវ បើចំនួនសរុបនោះ មិនត្រូវគ្នាទេ គឺលេខបូកនោះខុស ។

## រង្វាស់រង្វាល់

### អាទិត្យទី ១.– អំពីរង្វាស់ប្រវែង

ម៉ែត្រជាខ្នាតប្រធាននៃរង្វាស់ប្រវែង ។ ខ្នាតដែលធំជាងម៉ែត្រគឺ ដេកាម៉ែត្រ ( ដា. ម. ) ប្រវែង១០ម៉ែត្រ ។ ហិកតូម៉ែត្រ ( ហ. ម. ) ប្រវែង១០០ម៉ែត្រ ។ គីឡូម៉ែត្រ (គ. ម.) ឬ ១០០០ ម៉ែត្រ ។

សូមឲ្យសិស្សហាត់គិតមាត់ទទេ ឬរសេតួមួយទៅមួយដូចជាឲ្យរក ក្នុង ៤២៧ ហ. ម. មានប៉ុន្មានម៉ែត្រ ? ក្នុង ៨៧៣ ម៉ែត្រមានប៉ុន្មាន ដេកាម៉ែត្រ ។ល។

ឯខ្នាតដែលខ្លីជាងម៉ែត្រនោះគឺ ដេស៊ីម៉ែត្រ ( ដ. ម. ) សង់ទីម៉ែត្រ (ស.ម.) មីលីម៉ែត្រ ( ម. ម. )

### អាទិត្យទី ២.– អំពីខ្នាតប្រវែងដែលមានរូបជាប្រធាន ។

ទ្វេដេស៊ីម៉ែត្រខ្លីជាងម៉ែត្រ ៥ ដង ។ ១ម៉ែត្រ ។ កន្លះម៉ែត្រ ០ម ៥០ ។ កន្លះដេកាម៉ែត្រឬ៥ម៉ែត្រ ។ ១ដេកាម៉ែត្រឬ១០ម៉ែត្រ ។

សូមលោកគ្រូករង្វាស់ទាំងនេះមកបង្ហាញឲ្យសិស្សមើល ឲ្យប្រើវាស់វត្ថុផ្សេងៗ ឲ្យស្ទាត់ ។ សូមរើសការហាត់ដាក់ឲ្យធ្វើផងចុះ ។

## ធរណីមាណសាស្ត្រ

### អាទិត្យទី ១.— អំពីបន្ទាត់ផ្សេងៗ ។

ខ្ញុំយកអម្បោះមួយសរសៃទាញឲ្យតឹង ខ្ញុំបានជាបន្ទាត់មួយបែប។ ខ្ញុំយកក្រដាស១សន្លឹកបត់ជាពីរផ្នត់ៗ ក្រដាសនេះជាបន្ទាត់មួយដែរ ។ គំនូសខ្មៅ ៗ នៅលើសៀវភៅអ្នកក៏ជាបន្ទាត់ដែរ បន្ទាត់ទាំងនេះមានទំហំតែមួយគឺប្រវែង ។

បន្ទាត់មានច្រើនយ៉ាងផ្សេង ៗ ពីគ្នា គឺ

បន្ទាត់ត្រង់ បន្ទាត់កាច់ បន្ទាត់ផ្ដេក បន្ទាត់ទៀង បន្ទាត់ឈរ បន្ទាត់កោង បន្ទាត់ស្រប ។

លក្ខណៈនៃបន្ទាត់ ។— បន្ទាត់សំយុងត្រង់គឺបន្ទាត់ដែលគេត្រង់តាមខ្សែកូនប្រយោល (កូនតឹង) ។ បន្ទាត់ទៀងដែលត្រេតទៅធ្វេងឬទៅស្ដាំ ។ បន្ទាត់ផ្ដេកគឺជាបន្ទាត់ដែលគេត្រង់តាមផ្ទៃទឹក ។

បន្ទាត់ ២ ឬ ៣ ឬច្រើន កាលណាគេបន្ទាយទៅមិនជួបគ្នាសោះស្មានដូចផ្លូវដែករថភ្លើង ឬដូចចិញ្ចើមថ្នល់ ឈ្មោះថាបន្ទាត់ស្រប ។

ការហាត់ — ចូរឲ្យសិស្សគូសបន្ទាត់ដែលបានរៀនខាងលើនេះ ដាក់នៅលើក្ដារខៀនរួចដាក់ក្នុងសៀវភៅ ។

អាទិត្យទី ២ .—១ អំពីមុម ។

ប្រដាប់បង្រៀន — ដែកឈានតូច-ធំ, កែងទឹងក្រដាសក្រាស់-ស្ដើង ។

ក) ដូចម្ដេចដែលហៅថាមុម ។

ដងដែកឈានដែលគេវាតឲ្យឃ្លាតពីគ្នា ឬទ្វារបង្អួចដែលគេបើក កើតបានជាមុម ។




គ្រូគូសមុមផ្សេងៗនៅក្ដារខៀនឲ្យសិស្សមើលរួចឲ្យសិស្សគូសខ្លួនឯងវិញ ។

ខ) បន្ទាត់ កខ នឹងបន្ទាត់ ខគ ចេញពីកន្លែងចំណុចតែមួយដូចគ្នា ហើយដំរង់ទៅទិសផ្សេងគ្នា កើតបានជាមុមមួយគឺមុម កខគ ។

បន្ទាត់ កខ នឹងបន្ទាត់ ខគ គឺជាហាមមុមឬជ្រុងមុម ។

## ២- អំពីមុមទាំងឡាយ

គ្រូយកដែកឈានវាត់ធ្វើជាមុមផ្សេងៗ ឲ្យបានច្រើនឲ្យសិស្សពិនិត្យមើល គឺ មុមកែង មុមញាយ នឹងមុមស្រួច ។




## ៣- អំពីកំពូលនឹងទំហំមុម

បន្ទាត់ កខ នឹងបន្ទាត់ ខគ ជួបគ្នាត្រង់កន្លែង ១ ៗ កន្លែងចំណុចត្រង់ ១ នេះ ហៅកំពូលមុម កខគ ឯផ្ទៃដែលនៅកណ្ដាលរវាងបន្ទាត់ កខ នឹងបន្ទាត់ ខគ ហៅជាទំហំមុម ។ គ្រូយកក្រដាសបត់ជាមុមស្រួច មានហាមវែង ក្រដាស់១ទៀតបត់ជាមុមញាយមានខ្លីហើយដាក់មុមទាំងពីរនេះ ត្រួតលើគ្នាឲ្យសិស្សពិនិត្យមើលហើយសួរសិស្សថាមុមណាធំជាងណា ?



(មុមញាយធំជាងមុមស្រួច) ។ ដូច្នេះទំហំមុមមិនត្រូវគិតតាមប្រវែងហាមនោះទេ គេគិតតាមទំហំផ្ទៃមុម ។

៤– អំពីរបៀបមើលនិងសរសេរមុម ។

នឹងមើលឬនឹងសរសេរមុម គេត្រូវមើលឬសរសេរអក្សរកំពូលមុមដាក់ចំកណ្ដាលអក្សរឯទៀត ។




មុមនេះត្រូវសរសេរអក្សរដាក់ថាមុម កខប ហើយត្រូវមើលថាមុម កខប ដែរ ។

**ការហាត់.–** ឲ្យគូសមុមផ្សេង ៗ ដែលបានរៀនខាងលើនេះ (កុំភ្លេចប្រាប់សិស្សថា ក្នុងមុមនិមួយ ៗ ត្រូវប្រើអក្សរ ៣ តួ) ។

# គតិកដ្ឋាន

## នព្វន្ត

### បំនួនពី ១ ដល់ ១០០

លេខ បូក - រាប់ម្ដង ៧ , ម្ដង ៨

បង្កើន ឡើង ឬ បន្ថយចុះ

មតិសំខ្យា = ៦៩ + ២១. ១៥ + ២៥

---

សេចក្ដីសំខាន់ វេលាដែលបង្រៀន នព្វន្តម្ដង ៗ កុំឲ្យបង្រៀន តែលេខទទេ ត្រូវមានវត្ថុផ្សេង ៗ ដូចជាបន្ទះ, បំរៀក ឬស្សី, ដុំគ្រួស, ដងប៉ាកកា, លុយសេន, ដីស... ។ល។ ដើម្បីឲ្យសិស្សរៀនរាប់ ហើយឃើញច្បាស់លាស់នឹងភ្នែក ៕

របៀបបង្រៀន :

១) ការហាត់គិតមាត់ទទេៈ ឲ្យសិស្សរាប់បន្ថែមឬដុំគ្រួស ពី ១ ដល់ ១០០ បង្កើនម្ដង ៧ ម្ដង ៨ បន្ថយពី ១០០ ម្ដង ៧ ម្ដង៨ ៗ

២)ការហាត់បញ្ជាក់មើលចំនួន– ចង្អុលចំនួន ដែលសរសេរទុក នៅលើក្ដារខៀនឲ្យសិស្សមើលថា រួចសាកសួរអំពីខ្ទង់រាយ; ខ្ទង់ដប់, ខ្ទង់រយ ។

៣) ការហាត់បញ្ជាក់សរសេរចំនួននៅក្ដារខៀន

គ្រូសូត្រលេខឲ្យសិស្សសរសេរតាមដូចជាលេខ : ៩ ២១, ១២, ៤៤, ៥, ១៧, ៥៦, ៧៩, ៨៥, ។ល។

ការហាត់សរសេរនៅក្នុងសៀវភៅ ._

១៤ ស + ៦ ស = សេន

២៨ ស + ៩ ស = សេន

៤១ ស + ១៥ ស = សេន

៨៧ ស + ១៨ ស = សេន

៣៥ ស + .......ស = ៦៥ សេន

៣៩ ស + ........ស = ៧៦ សេន

៤៧ ស + ,.........ស = ៧ សេន

៥) បំណោទ. ១) ក្នុងច្បារមួយ មានដើមឈើ ៦០ ដើម ។ គេដាំថែម ១៥ ដើមទៀត ។ តើដើមឈើទាំងអស់មានប៉ុន្មានដើម ។

២) ឪពុកខ្ញុំគាត់ទិញមួក ១ ថ្លៃ ៩៤រ, គាត់លក់ទៅវិញបាន ចំណេញ ៥រ, ។ តើឪពុកខ្ញុំគាត់លក់មួកនោះថ្លៃប៉ុន្មាន ?

៣) ឈ្មួញម្នាក់ទិញស្រូវម្តង ២០ បាវ, ម្តងទៀត ៣៥ បាវ, ម្តងទៀត៥៦បាវ ។ តើឈ្មួញនោះ ទិញបានស្រូវទាំងអស់ប៉ុន្មានបាវ ? ។

**ការហាត់គិតលេខដោយមតិសំខ្យា**- ដូចជាលេខ: ១៩+២១

**របៀបទី ១**- គេគិតថា: ២០ បូកនឹង ២១ ត្រូវជា ៤១; ត្រូវជា ៤១; ៤១ ដក ១ ចេញ នៅសល់ ៤០ ។

**សេចក្តីពន្យល់**- ដើម្បីឲ្យស្រួលគិត គេបន្ថែម ១ ទៅលើ ១៩ ឲ្យបានជាលេខដុំ២០ឡើង ។ រួចគេបូកថា ២០+២១ត្រូវជា៤១; ឯ ៤១ នេះត្រូវដក១ចេញ ដែលយើងបន្ថែមទៅលើ ១៩ នោះ ។

**របៀបទី ២**- គេដក ១ ពី ២១ រួចយកទៅបូកបន្ថែមលើ ១៩ ត្រូវជា ២០ ។ លេខទាំង២ស្មើគ្នា គឺ ២០+២០ ត្រូវជា ៤០ ដូចជាលេខ ១៥+២៥

គេគិតថា ៥ បូកនឹង ៥ ត្រូវជា១០ ៗ ១០ បូកនឹង២០ ត្រូវ ៣០ ៣០ បូកនឹង ១០ ត្រូវជា ៤០ ៗ

ឬ ដក ៥ ពី ២៥ ចេញ យកទៅបន្ថែមលើ ១៥ ៗ លេខទាំង ២ ស្មើគ្នា គឺ ២០+២០ ត្រូវជា ៤០ ៗ

## រង្វាស់រង្វាល់

### ម៉ែត្រ -- លីត្រ -- បួនជ្រុងស្មើ

អាទិត្យដំបូង.– ម៉ែត្រ ជា រង្វាស់ខ្នាតដើម នៃវិធីវាស់ប្រវែង គេប្រើសំរាប់វាស់ប្រវែង ទទឹង បណ្ដោយ កំពស់ នឹងជំរៅវត្ថុទាំងឡាយដូចជា តុ ក្ដារងឿ ក្ដារខៀន បញ្ជរ បន្ទប់រៀន ដីស្រែ ភូមិ ចំការ ៗ ល ៗ ម៉ែត្រមានច្រើនយ៉ាង គឺម៉ែត្រ ឈើ បន្ទាត់ ម៉ែត្រឈើបត់ ម៉ែត្រដែក ឬស្ពាន់បត់ ម៉ែត្រសំពត់ ៗ

ពិតមែនតែម៉ែត្រមានច្រើនដូច្នេះ តែប្រវែងម៉ែត្រទាំងនេះស្មើគ្នាទាំងអស់ ជាខ្នាតទៀងណាស់ ហើយបានជាគេធ្វើឲ្យមានច្រើនបែបយ៉ាងនេះ គឺឲ្យ

ងាយដល់អ្នកប្រើការ ដូចជាឈ្មួញសំពត់ ប្រើម៉ែត្របន្ទាត់ ជាងធ្វើផ្ទះជាងឈើប្រើម៉ែត្របត់ ធ្វើនឹងឈើ ឬធ្វើនឹងដែក ជាងដេរខោអាវប្រើម៉ែត្រសំពត់ ។ សូមយកម៉ែត្រគ្រប់បែបមកបង្ហាញសិស្សឲ្យមើល ឲ្យសង្កេតឲ្យបានគ្រប់គ្នា ។

ម៉ែត្រ គេសរសេរកាត់ "ម" ដូចជា ១ម, ៥ម, ៧ម,....... ។

ការហាត់គិតមាត់ទទេ ម៉ែត្រសំរាប់ធ្វើអ្វី ? ម៉ែត្រមានប៉ុន្មានយ៉ាង ? ម៉ែត្រអ្វីខ្លះ? ម៉ែត្រណាវែងជាងគេ? ហេតុអ្វីបានជាគេធ្វើម៉ែត្រច្រើនយ៉ាងដូច្នេះ? ជាងដេរខោអាវប្រើម៉ែត្រអ្វី? ជាងឈើប្រើម៉ែត្រអ្វី?

ការហាត់វាស់ និង ហាត់ស្មានប្រវែង បង្ហាញ បណ្ដោយតុ កំពស់ក្ដារខៀន ជំរៅធុងទឹក ឲ្យសិស្សស្មាន ប្រវែង រួចនាំសិស្សឲ្យវាស់ឲ្យបានច្រើនគ្នា ។

បំណោទ — ១) ជាងដេរខោអាវម្នាក់ប្រើសំពត់អស់ ២ម, ក្នុងកាត់ខោមួយ ៗ ក្នុងសំពត់ ១៤ម, តើកាត់បានខោប៉ុន្មាន? ។

២) ចិនម្នាក់ទិញសំពត់ ៣៩ ម៉ែត្រ ហើយលក់ ៦ ម៉ែត្រទៅវិញ តើចិននោះនៅសល់សំពត់ប៉ុន្មានម៉ែត្រទៀត? ។

៣) ឈ្មួញម្នាក់ទិញខ្សែលួសម្តង ៧៥ ម៉ែត្រម្តងទៀត ២៥ ម៉ែត្រ ឈ្មួញនោះយកទៅលក់វិញអស់ ៥៣ ម៉ែត្រ តើនៅសល់ខ្សែលួសប៉ុន្មានម៉ែត្រលក់ទៅមុខទៀត ? ។

## អាទិត្យបន្ទាប់ :- អំពីលីត្រ

សូមរករង្វាល់មកឲ្យសិស្សពិនិត្យ បើគ្មានសូមឲ្យបង្ហាញគំនូរ ឬគូរនៅលើក្តារខៀនឲ្យមើល ។

លីត្រជារង្វាល់ ប្រើសំរាប់វាល់វត្ថុរាវ ដូចជា ស្រា ប្រេង ខ្លាញ់ ទឹក និងវត្ថុគ្រៀម ឬគ្រាប់ ដូចជាអង្ករ ស្រូវ សណ្តែក ល្ង ។ល។

លីត្រមានចំណុះស្មើគ្នាទាំងអស់ ប៉ុន្តែមានរាង ឬ បែបខុសគ្នា រង្វាល់លីត្រដែលមានជាក់ស្តែងនោះមាន ៣ យ៉ាង ។

១)- លីត្រធ្វើពីដែកស៊ីវិឡាត ឬសំណប៉ាហាំង មានដៃកាន់ពីក្រោយ សំរាប់វាល់ខ្លាញ់ ប្រេង ទឹក ។ល។

២)- លីត្រធ្វើពីស្ពាន់ស មានដៃយួរសំរាប់វាល់ស្រា ទឹកដោះគោ ទឹកសាអ៊ីវ ។ល។

៣)- លីត្រធ្វើពីឈើ សំរាប់វាល់វត្ថុគ្រៀម ដូចជាម្សៅពោតអង្ក

ស្រូវ ល្ង សណ្តែក ។ មានលីត្រ ១ យ៉ាងទៀត ហៅថាលីត្រដប ។

ឯលីត្រដបនេះគេធ្វើសំរាប់ដាក់ស្រា ដាក់ទឹកថ្នាំ នឹងវត្ថុឯទៀតរាវ ដូចជាទឹក ។ លីត្រដបនេះ ពុំមែនប្រើសំរាប់វាស់ដូចជាលីត្រឯទៀតនោះទេ គឺគេធ្វើសំរាប់ដាក់ស្រាថ្នាំឲ្យដឹងចំនួនទឹងកំណត់ ។

**ហាត់គិតមាត់ទទេ.**— គេហៅវង្វាល់ ដែលជាប្រធានមានជាក់ស្ដែងគឺអ្វី ? បើគេចង់ដឹងចំនួនវត្ថុរាវ ដែលគេថ្លឹងពុំបាននោះ គេធ្វើដូចម្ដេច ? លីត្រជាអ្វី ? មានប៉ុន្មានយ៉ាង ? លីត្រឈើសំរាប់ប្រើធ្វើអ្វី ?

សូមសួរណែនាំពីបែបលីត្រដែលមានផ្សេង ៗ ហើយនឹងប្រយោជន៍នៃលីត្រនិមួយ ៗ ។

សូមឲ្យសិស្សដឹងជាក់ច្បាស់ថា វង្វាល់ឯណាឈ្មោះថាលីត្រនោះ មានបំណុះស្មើគ្នាតាំងអស់ ។ ប្រាប់សិស្សថា ខ្មែរយើងពុំមានទម្លាប់ប្រើលីត្រទេ សន្មតគ្នាយកចានប្ដែងមកប្រើ ម្ល៉ោះហើយពុំដែលបានទៀងទាត់ដោយចានប្ដែងមានតូចមានធំ ។

នាំសិស្សឲ្យចេះវាស់វត្ថុផ្សេង ៗ ដូចជា ទឹក អង្ករ ស្រូវ ពោត

សណ្តែក ៗ ប្រាប់សិស្សឲ្យច្បាស់ថា ក្នុង ១ តៅ មាន ១៥ លីត្រ ក្នុង ១ ប៉ោត មាន ១៨ លីត្រ នោះជាទៀងទាត់ ៗ

## ការហាត់សរសេរ នឹង បំណោទ

៦១ល + ១៨ល = ល.

៣៨ល + ១៦ល = ល.

៥៦ល − ២២ល = ល.

៨៩ល − ៥៨ល = ល.

១)- នៅក្នុងក្រឡមួយមានស្រា ៣៣ លីត្រគេជួសលក់អស់ ១៨ លីត្រ ៗ តើនៅសល់ស្រាប៉ុន្មានលីត្រទៀត ក្នុងក្រឡនោះ ?

២)- ទឹកនៅក្នុងធុងមាន ៩៣ លីត្រ គេប្រើការអស់ ២៨ លីត្រ ហើយ ដងចាក់មកវិញ ១៩ លីត្រ ៗ តើនៅក្នុងធុងមានទឹកប៉ុន្មានលីត្រ ? ៗ

## បួនជ្រុងស្មើ

មេរៀននេះ នៅតែក្នុងរង្វាស់រង្វាល់ដដែលមិនមែនបញ្ចូលទៅក្នុងធរណីមាណសាស្ត្រទេ ៗ ក្នុងមេរៀននេះ សូមបង្ហាញ សិស្សឲ្យស្គាល់បួនជ្រុងស្មើនឹងឲ្យចេះរកបរិវេណប៉ុណ្ណោះទេ ៗ

## ការហាត់សំគាល់បួនជ្រុងស្មើ-

គូរបួនជ្រុងស្មើ នៅក្ដារខៀន បង្ហាញប្រវែងជ្រុងទាំងបួន (ស្មើគ្នាទាំងអស់) ។ អង្កត់ពណ៌ ក្រាល ជាបួនជ្រុង កាត់ក្រដាសជាបួនជ្រុងស្មើ បង្ហាញសិស្ស ។



៤សម. ៤សម.

**ន័យ.**- បួនជ្រុងស្មើ គឺ ចតុរង្ស ដែលមានជ្រុងទាំងបួនស្មើគ្នា ។

## ការហាត់រកបរិវេណ.-

នាំសិស្សឲ្យសង្កេតគំនូរខាងក្រោមនេះ ៖




បរិវេណ នៃបួនជ្រុងស្មើ គឺប្រវែងជ្រុងមួយ ៗ បួនដង ឬ: ១សម + ១សម + ១សម + ១សម ឬ

១ + សម + ៤ = ៤សម

**ន័យ.**- បរិវេណនៃបួនជ្រុងស្មើ គឺប្រវែងជ្រុងស្មើទាំងបួនរួមគ្នា ។

## ការហាត់ គិតមាត់ទទេនឹងហាត់សរសេរ -

យ៉ាងដូចម្ដេចដែលហៅថា បួនជ្រុងស្មើ ?

របស់អ្វីខ្លះ ដែលមានរាងដូចបួនជ្រុងស្មើ ?

ត្រូវធ្វើដូចម្ដេច ដើម្បីនឹងរកប្រវែងបរិវេណបួនជ្រុងស្មើ?

## ការហាត់គិតសរសេរ

សូមរកបរិវេណបួនជ្រុងស្មើដែលមានជ្រុងនិមួយ ៗ ប្រវែង ១២ ម? ១៥ ម? ៣០ ម? ៥០ ម?

បំណោទ – ១) – ច្បារដំណាំមួយ មានរៀងបួនជ្រុងស្មើ ។ ជ្រុងមួយ ៗ ប្រវែង ៣២ ម គេព័ទ្ធខ្សែលួសបន្លាជុំវិញច្បារនោះ ៣ ជុំ ធ្វើជារបង ។

គេប្រើខ្សែលួសអស់ប៉ុន្មានម៉ែត្រ? ។

---

## បឋមដ្ឋានទី ១

គព្ទ

ចំនួន ពី ១ ដល់ ១០០

លេខបូក – លេខសង – ចំណោទខ្លីៗ –

សូមបង្រៀនតាមរបៀបបង្រៀននៅថ្នាក់អាទិកដ្ឋានៗ សូមរើសចំណោទឲ្យបានច្រើនឲ្យសិស្សធ្វើឲ្យបានគ្រប់គ្រាន់

## រង្វាស់រង្វាល់

១) អំពីម៉ែត្រ.– សូមបង្រៀនតាមថ្នាក់អាទិកដ្ឋានៗ

២) អំពីលីត្រ.– សូមបង្រៀនតាមថ្នាក់អាទិកដ្ឋាក ៗ

៣) អំពីក្រាម.– វត្ថុដែលគេវាល់មិនបានវាស់ពុំកើតនោះ គេត្រូវថ្លឹងទម្ងន់ គេថ្លឹងនឹងជញ្ជីង ហើយនឹងកូនទម្ងន់ ឯកូនទម្ងន់សំរាប់ថ្លឹងទំនិញឬរបស់ស្រាលៗនោះគឺក្រាមៗ ក្រាមជាដុំស្ពាន់តូចមូលមានក្បាលមូលតូចសំរាប់កាន់ៗ ក្រាម គេសរសេរយ៉ាងដូច្នេះ "ក្រ" ៗ

វិធីហាត់ថ្លឹង.– សូមយកជញ្ជីង កូនទម្ងន់ក្រាម ហើយនឹងវត្ថុសំរាប់ថ្លឹងនោះមកបង្ហាញសិស្សមើល ហើយប្រាប់របៀបថ្លឹង រួចហើយឲ្យសិស្សរៀនថ្លឹងឲ្យបានច្រើនគ្នា លុះត្រាតែចេះចំណាំទម្ងន់វត្ថុ ជានេះ ១ក្រាម - ៥ក្រាម - ១០ក្រាម ៗ

ហាត់គិតមាត់ទទេ .– គេចូនរបស់សព្វសារពើនឹងអ្វី ? ។ ពីព្រោះអ្វីបានជាគេចូន ។ វត្ថុណាខ្លះដែលគេត្រូវចូន ។ និងចូនគេធ្វើដូចម្ដេចខ្លះ ? ។

៤)អំពីរូបិយវត្ថុស្រុកអាយ .– (ប្រទេសកម្ពុជា).

របស់ដែលគ្រូយកមកបង្រៀន .– ប្រាក់ ១ រៀល ក្រដាស ១ រៀលគ្រប់យ៉ាង ជាន់ដើមនឹងបេញថ្មី ក្រដាស ៥ រៀល ក្រដាស ១០ រៀល ក្រដាស ២០ រៀល (ជាន់ចាស់នឹងថ្មី) ក្រដាស ៥០ រៀល ក្រដាស ១០០ រៀល (ចាស់នឹងថ្មី) ក្រដាស ៥០ សេន, ២០ សេន, ១០ សេន, ៥ សេន,

រូបិយវត្ថុធ្វើអំពីលោហជាតុ – ប្រាក់ ៥០ សេន, ២០ សេន, ១០ សេន, លុយ ៥ សេន, ទីង ១ សេន,

របៀបបង្រៀន – នឹងសង់ថ្លៃទំនិញដែលត្រូវការទិញ គេត្រូវការនឹងរូបិយវត្ថុ រូបិយវត្ថុប្រើបាននៅនាប្រទេសកម្ពុជា គឺរៀល សារសេរកាត់ (រ) ។ រៀលមានប៉ុន្មានយ៉ាង ។ ហេតុអ្វីបានជាគេធ្វើរូបិយវត្ថុស្រុកអាយ អំពីក្រដាសផង ។

សូមបង្ហាញក្រដាសប្រាក់គ្រប់យ៉ាង ហើយរាប់ឲ្យសិស្សមើលសិន

ការហាត់ឲ្យចេះប្រើប្រាស់ដូរប្រាក់ = ឲ្យសិស្សដូររូបិយវត្ថុ ឧបមាដូចជាដូរក្រដាស ១០០ រៀល យកជាក្រដាស ៥០ រៀលខ្លះ ២០ រៀលខ្លះ ១០ រៀលខ្លះ ៥ រៀលខ្លះ និង ១ រៀលខ្លះ ។

ការហាត់លើក្តារឆ្ពន .— នាម៉ឺនម្នាក់ទិញស្បែកជើង ១ សំរាប់ ថ្លៃ ១៩៥ រៀល ស្រោមជើងវែង ១ គូថ្លៃ ៣៧ រៀល ហិបស្បែក ១ ថ្លៃ ៣៥៥ រៀល ។ នាម៉ឺននោះឲ្យក្រដាស ១០០ រៀល ប្រាំមួយសន្លឹក ទៅឈ្មួញ តើឈ្មួញត្រូវថែមប៉ុន្មានមកវិញ ? តើក្រដាសប្រាក់អ្វីខ្លះ ?

ការហាត់សរសេរ .— ដើម្បីនឹងសងថ្លៃទំនិញ ៨០ រៀល ខ្ញុំឲ្យក្រដាស ៥ រៀល . . . . សន្លឹកក៏បាន ។ ក្រដាស ២០ រៀល . . . . សន្លឹក នឹងក្រដាស ៥ រៀល . . . . សន្លឹកក៏បាន ។

## ធរណីមាត្រសាស្ត្រ

### បន្ទាត់ផ្សេង ៗ

ខ្ញុំយកអម្បោះមួយសរសៃទាញចុងដើមឡើងតឹង ខ្ញុំបានជាបន្ទាត់មួយថែប ៗ គំនូសទៅៗ នៅលើសៀវភៅសរសេរ ក៏បន្ទាត់ដែរ ៗ ទ្រ-នុងតុក៏ជាបន្ទាត់មួយដែរ

បន្ទាត់មានទំហំតែមួយគឺប្រវែង ៗ

**រាងនៃបន្ទាត់.** **១– បន្ទាត់ត្រង់** គឺជាផ្លូវខ្លីបំផុតពីចំណុចមួយទៅចំណុចមួយ ៗ




បន្ទាត់ត្រង់

**២– បន្ទាត់កាច់.–** កើតពីបន្ទាត់ត្រង់ច្រើនតគ្នា ៗ




បន្ទាត់កាច់

**៣.– បន្ទាត់កោង.–** គឺជាបន្ទាត់មិនមែនត្រង់ មិនមែនកាច់ ៗ




បន្ទាត់កោង

**ស្ថានភាពរបស់បន្ទាត់ត្រង់.–** ផ្ទៃទឹកក្នុងកែវមានសណ្ឋានជាបន្ទាត់ផ្ដេក ៗ ខ្សែកូនតឹងដែលសំយុងត្រង់ចុះ មានលំនាំជាបន្ទាត់ឈរ ផ្ទាំងដំបូលផ្ទះ មានសណ្ឋានជាបន្ទាត់ទៀង ៗ –

សូមគ្រូហ៊ឹកសិស្សឲ្យស្គាល់ស្ថានភាពបន្ទាត់នេះ ដោយឲ្យគូរតំនូរ ដូចខាងក្រោមនេះ ។




# កុមារដ្ឋាន

## គណិត

មេរៀនទី ១ .– ចំនួនពី ១ ដល់ ៤ - ការរៀនរាប់ - រៀនមើល រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន .– បន្ទះឬគ្រាប់គ្រួសឬលុយសេន ។

របៀបបង្រៀន.–១–ការរៀនរាប់ចំនួន.– គ្រូលើកចង្កឹះ ១ ឬគ្រាប់គ្រួស ១ ឬលុយសេន ១ បង្ហាញសិស្សរួចប្រាប់ថា "នេះចង្កឹះ១" ហើយគូសគំនូសមួយនៅលើក្ដារខៀន ។

២ – គ្រូសរសេរចំនួន ១ នៅលើក្ដារខៀននៅក្រោម គំនូស ហើយនាំសិស្សរៀនមើលថាលេខ ១ នោះ

៣ – គ្រូពន្យល់របៀបសរសេរលេខ ១ ហើយ នាំសិស្សរៀនសរសេរលេខនោះដើមដំបូងដោយដៃទទេបង្ហើរដោយខ្យល់ រួចឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន ។

ការបំណាំ .– សុំនាំសិស្សឲ្យសរសេរឲ្យបានល្អកុំអោយច្រស័យឲ្យសោះ ព្រោះកាលណាវាបានចេះសរសេរល្អពីដំបូងហើយ វានឹងធ្លាប់សរសេរល្អរហូតដល់ថ្ងៃក្រោយ ដូចគំរូនេះ (១-២-៣-៤-៥) កាលណាសិស្សស្គាល់ - ចេះមើល - ចេះសរសេរចំនួន ១ នេះច្បាស់ហើយ សឹមចាប់បង្រៀនលេខ ២-៣-៤-៥ តទៅទៀតតាមរបៀបខាងលើនេះ ។

ការហាត់បញ្ជាក់ឡើងវិញ .–

១ – បញ្ជាក់អំពីការរៀនរាប់ចំនួន .– គ្រូលើកចំនួនរបស់ ១

៣.៥.២.៤ បង្ហាញសិស្សឲ្យរាប់ជាចំនួន រួចជាចំនួនឲ្យសិស្សបង្ហាញរបស់វិញ ។

២ – បញ្ជាក់អំពីការរៀនមើលចំនួន.- គ្រូបង្ហុលចំនួននៅលើក្ដារដែលសរសេរទុកឲ្យសិស្សថា រួចជាចំនួនឲ្យសិស្សបង្អុលលេខនៅលើក្ដារខៀន ។

៣ – ការបញ្ជាក់អំពីសរសេរចំនួន.– គ្រូជាចំនួនឲ្យសិស្សសរសេរលេខនៅលើក្ដារឆ្នួន ។

## មេរៀនទី ២.– ចំនួនពី ៦ ដល់ ៩ – ការរៀនរាប់ – រៀនមើល រៀនសរសេរចំនួន ។

សូមធ្វើតាមរបៀបដែលបង្រៀនចំនួនពី ១ ដល់ ៥ ប៉ុន្តែមុននឹងបង្រៀនចំនួនពី ៦ ដល់ ៩ សូមសាបញ្ជាក់អំពីចំនួនដែលបានរៀនពីថ្ងៃមុនសិន ។

## មេរៀនទី ៣.– ចំនួនដល់ ៩ – រៀនធ្វើលេខបូក ។

របស់សំរាប់បង្រៀន.– បន្ទះ ប្លាស្រគាប់គ្រួស ប្លាស្ទុយសេន ។

## របៀបបង្រៀន .–

១– ការហាត់គិតមាត់ទទេ.– នាំសិស្សរៀនរាប់ចង្កឹះឬគ្រាប់គ្រួស ឬលុយសេនបន្ថែមមួយ ៗ. ពីរ ៗ. បី ៗ ពី ១ ដល់ ៩ ។

២– ការពន្យល់របៀបធ្វើលេខបូក ដូចជាសិស្សម្នាក់មានចង្កឹះ ៣ ម្នាក់ទៀតមានចង្កឹះ ២ តើសិស្សទាំងពីរនាក់នោះមានចង្កឹះប៉ុន្មាន ? ។ គ្រូធ្វើលេខបូកនៅលើក្ដារខៀន ពន្យល់សិស្សអំពីរបៀបតាំងលេខ ដាក់សញ្ញានិងធ្វើលេខ

$$\begin{array}{r} ៣ \\ +\ ២ \\ \hline ៥ \end{array}$$

៣– ការហាត់បញ្ជាក់នៅលើក្ដារខៀន ៖ ២ × ៤ = . . ។ ៥ × ២ = . . . ។ ៣ × ៤ = . . . ។ល។

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន ៖ ៣ × ៥ = . . . ។ ៥ × ៤ = . . . ។ ២ × ៦ = . . . ។ល។

## មេរៀនទី ៤.– ចំនួនដល់ ៩ – លេខសង

សូមធ្វើតាមរបៀបបង្រៀនលេខបូកខាងលើនេះ

## រង្វាស់រង្វាល់

មេរៀនទី ១.– អំពីរង្វាស់ម៉ែត្រ ។

របស់សំរាប់បង្រៀន.– ម៉ែត្របត់ឬម៉ែត្របន្ទាត់

របៀបបង្រៀន.– ១ – គ្រូលើករង្វាស់ម៉ែត្របង្ហាញសិស្ស ហើយសួរឬប្រាប់សិស្សថា រង្វាស់នេះហៅថាម៉ែត្រ – មានប្រវែង ១ ម៉ែត្រ ។

២ - នាំសិស្សពិនិត្យមើលរង្វាស់នេះឲ្យស្គាល់ប្រវែង ១ ម៉ែត្រ - ការសំខាន់គឺឲ្យសិស្សស្គាល់ប្រវែង ១ ម៉ែត្រ

៣ - ការហាត់ស្មាន- –ឲ្យសិស្សស្មានប្រវែង១ម៉ែត្រដោយគូសគំនូសនៅលើក្ដារខៀន ហើយវាស់បញ្ជាក់ ឬឲ្យស្មានប្រវែងរបស់អ្វីមួយដែលមានប្រវែង ១ម. ២ម ៣ម ។

សូមធ្វើការហាត់ស្មាននេះឲ្យបានច្រើន ព្រោះការសំខាន់បំផុតក្នុងការបង្រៀននេះគឺឲ្យសិស្សស្គាល់ប្រវែង ១ ម . ហើយចេះស្មានបណ្ដោយវត្ថុទាំងឡាយដោយភ្នែកពុំចាំបាច់មានរង្វាស់មកវាស់ ។

៤ . ការហាត់គិត . — នាំសិស្សហាត់គិតដោយមាត់ទទេជាចំ-ណោទងាយៗ ដូចជាខ្សែមួយប្រវែង ៤ ម, គេយកទៅតនឹងខ្សែទៀតប្រវែង ៥ ម, ហើយគេកាត់យក ៧ ម, បេញតើខ្សែនោះនៅសល់ប្រវែងប៉ុន្មានម៉ែត្រ ។

## មេរៀនទី៣ អំពីរង្វាស់ម៉ែត្រ (ត)

សូមធ្វើតាមរបៀបខាងលើនេះ ដោយបង្ហ្វឹកសិស្សឲ្យចេះក្ដួនចេះប្រើប្រាស់រង្វាស់ម៉ែត្រឲ្យស្ទាត់ ហើយសូមតែងការហាត់តាមរបៀបខាងលើផងៗ

---

# បរិច្ឆណាដ្ឋាន

ឆ្នាំ ១

## មេរៀនទី ១ . — សាបញ្ញាកអំពីចំនួនពី១ ដល់ ១០០

១ . — ការហាត់គិតមាត់ទទេ . — ឲ្យសិស្សរាប់បង្កើនបន្ថែម ពីរៗ បីៗ បួនៗ ពីមួយដល់មួយរយរាប់បន្ថយពីមួយរយមកមួយវិញ ៗ

២ – បញ្ជាក់អំពីការរៀនរាប់ចំនួន-ដូចជា៖មានដប់ប៉ុន្មានទីដ៏កាយប៉ុន្មានក្នុងចំនួន ១៥-២៧-៣៩-៤១-៥៨-៦៣-៧៤-៨៥-៩៧. . .

៣ – បញ្ជាក់អំពីការរៀនមើលចំនួន.-គ្រូបង្អុលចំនួនដែលសរ-សេរទុកនៅលើក្ដារខៀនឲ្យសិស្សថា រួចថាចំនួនឲ្យសិស្សបង្អុល

៤ – បញ្ជាក់អំពីការសរសេរចំនួន-គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន

៥ - ការហាត់សរសេរក្នុងសៀវភៅ.-

ក .- ចូរគិតចំនួនខាងក្រោមនេះ

១៥ស – ៣ស = . . . ។ ១៩ស + ២ស = . . . ។

២៧ស – ៣ស = . . . ។ ៣៩ស – ៣ស = . . ។

៤១ស – ៣ស = . . . ។ ៥២ស – ៣ស = . . . ។

៧៩ស – ២ស = . . . ។ ៨៥ស – ២ស = . . . ។

១- បំណោទ .– ខ្ញុំមានលុយ ១៩ សេន បងខ្ញុំឲ្យខ្ញុំ ៣ សេនទៀត ខ្ញុំត្រូវមានលុយទាំងអស់ . . . .សេន ។ បើជាខ្ញុំចាយអស់៧ សេនទៅ ខ្ញុំត្រូវនៅសល់លុយ . . . . សេនទៀត ។

មេរៀនទី ២_. ចំនួនដល់ ១០០ - លេខបូកចំនួនដុំឥតត្រាទុក-មានត្រាទុក ។

របៀបបង្រៀន .– ១ – ការហាត់គិតមាត់ទទេ .– ឲ្យសិស្សរាប់បង្កើនបន្ថែមពីរៗ បីៗ បួនៗ ពី១ដល់ ១០០ ។

២ – ពន្យល់របៀបធ្វើលេខបូកនៅលើក្ដារខៀន-ដូចជា៖ ខ្ញុំមានលុយ ២៣ សេន - ម្ដាយខ្ញុំឲ្យខ្ញុំ ៣៤ សេនទៀត ខ្ញុំត្រូវមានលុយប៉ុន្មានសេន ?

| | |
|---|---|
| ២៣ ស | ១៧ ស |
| + ៣៤ ស | + ៤៣ ស |
| ៥៧ ស | ៦០ ស |

៣ – ការហាត់បញ្ចូលនៅលើក្ដារខៀននឹងលើក្ដារឆ្នួន

១៤ ស + ២៣ស = ? ៤២ ស + ៣១ ស = ? ៥៤ ស + ២៤ ស = ?

២៥ ស + ៣៧ ស = ? ៤៦ ស + ៣៥ ស = ? ៥៨ ស + ៣៥ ស = ?

៤ – ការហាត់សរសេរក្នុងសៀវភៅ .

| | | | |
|---|---|---|---|
| ២៤ ស | ៣៥ ស | ៤៣ ស | ៥៧ ស |
| + ៣២ ស | + ៤៧ ស | + ២៤ ស | + ២៩ ស |
| | | | |

បំណោទ .– ខ្ញុំទិញសៀវភៅមើល ១ ថ្លៃ ១៧ រៀលនឹងដងប៉ាកកាស្រូបទឹកខ្មៅមួយថ្លៃ ២៥ រៀល ខ្ញុំចាយអស់ ...... រៀល ?

មេរៀនទី ៣.– ចំនួនដល់ ១០០ · លេខសង់ផុំឥតគ្រាទុកនឹង មានគ្រាទុកសូមធ្វើតាមរបៀបបង្រៀនលេខបូកខាងលើនេះ ។

---

## រង្វាស់រង្វាល់

### មេរៀនទី ១.– អំពីរង្វាស់ម៉ែត្រ (ម).

សូមមើលតាមរបៀបរៀបចំបង្រៀននៅកុមារដ្ឋាន ហើយសូម តែងការហាត់ឲ្យសព្វគ្រប់ផង ។

### មេរៀនទី ២.– អំពីរង្វាស់ម៉ែត្រ (ត)

អំពីម៉ែត្រគ្រប់បែប ៖ ម៉ែត្របត់ - ម៉ែត្របន្ទាត់ - ម៉ែត្រសំពត់ ។

**របស់សម្រាប់បង្រៀន.–** មានម៉ែត្រគ្រប់បែបនឹងរបស់សំរាប់ វាស់ ដូចជាខ្សែ

**របៀបបង្រៀន .–**

១– សួរសាបញ្ជាក់អំពីម៉ែត្រ

២– បង្ហាញម៉ែត្រគ្រប់បែបឲ្យសិស្សមើល ហើយនាំសិស្សពិនិត្យមើលម៉ែត្រ ១ បែប ៗ ឲ្យសព្វគ្រប់ ។

៣– ការហាត់ប្រើប្រាស់ម៉ែត្រ ១ បែបៗ គឺនាំសិស្សរៀនធ្វើជាជាងសង់ផ្ទះដោយប្រើម៉ែត្របត់ ធ្វើជាអ្នកលក់សំពត់ដោយប្រើម៉ែត្របន្ទាត់ ធ្វើជាអ្នកកាត់ដេរខោអាវដោយប្រើម៉ែត្រសំពត់ ។

៤– ការហាត់គិតមាត់ទទេ –

៥– ការហាត់សរសេរនៅក្នុងសៀវភៅ សូមតែងការហាត់ខាងលើនេះឲ្យសព្វគ្រប់ផង ។

---

## មជ្ឈិមដ្ឋានទី ២

## ក – វិទ្យាសាស្ត្រ

មេរៀនក្នុងខែកញ្ញា) – ១ អំពីខ្លួនមនុស្ស - ២ - អំពី អង្គសន្ធិលិក –
៣ - អំពីសាច់ដុំ – ៤ - អំពីគ្រឿងប្រដាប់វិញ្ញាណ

មេរៀនទាំងនេះសឹងមានក្នុងសៀវភៅវត្ថុស្វាធ្យាយន៍ ថ្នាក់អាទិកដ្ឋាន ត្រង់ទំព័រ ទី ៥ - ៦ - ១១ ទឹង ១៧ ប្រហែលជាគ្រប់គ្រាន់

ហើយ តែសូមបន្ថែមសេចក្ដីខ្លះទៀតប្រយោជន៍ឲ្យសំគាមថ្នាក់មធ្យម-ដ្ឋាននឹងឧត្តមដ្ឋានផង ។

មួយវិញទៀត. កាលពីឆ្នាំសិក្សា ១៩៥០-៥១ (ខ្ញុំបានជូនមេរៀនជាគំរូ អំពីខ្លួនមនុស្ស ព្រមទាំងសេចក្ដីណែនាំក្នុងការបង្រៀនវិទ្យា-សាស្ត្រ ដែលបានចុះក្នុងទស្សនាវដ្ដីនៃឆ្នាំទី ២ លេខ ១ ត្រង់ទំព័រលេខ ៥៨ ដល់ ៦០-។ ឥឡូវនេះសូមជូនមេរៀនជាគំរូដូចមានតទៅ ។

## មេរៀនជាគំរូ

## អំពីអដ្ឋិសង្ខលិកៈ

ប្រដាប់សំពប់បង្រៀន ។ សុំឲ្យសិស្សរកឆ្អឹងផ្សេង ៗ មានឆ្អឹងជើង — ឆ្អឹងក្បាលនៃសត្វគោ ឬសត្វឯ ៗ ទៀត ។ល។ សូមលោកគ្រូយកផ្ទាំងគំនូរនៃអដ្ឋិសង្ខលិក មកដាក់នៅមុខសិស្ស ហើយនាំសិស្សពិនិត្យមើលរូបឆ្អឹងតាមរបៀបសិក្សា ។

មេរៀនសង្ខេប.— ឆ្អឹងក្នុងខ្លួនយើងទាំងមូលផ្គុំគ្នាហៅថាអដ្ឋិសង្ខលិក ។ លលាដ៍ក្បាលមានឆ្អឹង ៨ បំណែក បន្ទំជាប់គ្នាដូចជាប្រអប់មួយ· ហៅថាឆ្អឹងលលាដ៍ក្បាល ។ នៅខាងមុខមានឆ្អឹង ១៤ បំណែក ឆ្អឹងទាំងនេះបន្ទំជាប់នឹងឆ្អឹងលលាដក្បាល លើកតែឆ្អឹង

ថ្គាមក្រោម អាចឲ្យកំរើកបាន ប្រយោជន៍នឹងទំពាអាហារដែលបរិភោគ ឆ្អឹងក្បាលបន្តជាប់ទៅឆ្អឹងដងខ្នងនឹងអង្កែក ។

អដ្ឋិសន្ធិលិកអវយវៈលើ តជាប់ទៅដងខ្នង នឹងឆ្អឹងដងកាំបិត ហើយនឹងឆ្អឹងស្មាបប្រជៀវ ។ អវយវៈលើមានឆ្អឹងដើមដៃ កំភួនដៃ នឹងឆ្អឹងម្រាមដៃតាំងប្រាំទៅខាងចុង ។ ឆ្អឹងអវយវៈក្រោម តជាប់ទៅឆ្អឹងដងខ្នង នឹងឆ្អឹងត្រគាក មានឆ្អឹងភ្លៅ កំភួនជើង នឹងឆ្អឹងជើង ។ នៅខាងចុងជើងមានឆ្អឹងម្រាមជើង៥ ដូចជាម្រាមដៃដែរ ។

ពាក្យសួរក្នុងមេរៀន = យ៉ាងដូចម្តេចហៅថាអដ្ឋិសន្ធិលិកៈ ។ អដ្ឋិសន្ធិលិកមានអ្វីខ្លះ? ។ នៅក្បាលមានឆ្អឹងអ្វីខ្លះ? ។ ឆ្អឹងជំនីរមានប៉ុន្មានគូ? ។ តើវាជាប់ទោឯណាខ្លះ? ។ យើងមានអវយវៈអ្វីខ្លះ? ។ អវយវៈលើជាប់ទៅដងខ្នងដូចម្តេច? ។ មានចំណែកអ្វីខ្លះ ។ល។

## អនាម័យ

### អំពីការសំអាតខ្លួន

យើងមិនគ្រាន់តែដកដង្ហើមចេញចូល តាមច្រមុះឬមាត់នោះទេ ប្រយោជន៍ឲ្យមានជីវិតរស់នៅ យើងត្រូវឲ្យមានញើសចេញចូល តាម

គ្រប់រន្ធរោមទៀតផង ដូច្នេះយើងត្រូវថែរក្សាស្បែកយើងឲ្យស្អាតជាដរាប ដើម្បីឲ្យបានសេចក្តីសុខសប្បាយក្នុងខ្លួនយើង ។ ដើម្បីឲ្យបានសេចក្តីក្សេមក្សាន្ត យើងត្រូវដុសលាងខ្លួនយើង ឲ្យសព្វគ្រប់ទាំងអស់ បើយ៉ាងហោចណាស់ ត្រូវដុសលាងខ្លួនយើងនឹងសាប៊ូឲ្យបានពីរដងក្នុងមួយអាទិត្យ គឺទៅថ្ងៃអាទិត្យនឹងថ្ងៃព្រហស្បតិ៍ ។ បើសិនណាជាយើងដុសលាងខ្លួនបានរាល់ថ្ងៃ ក៏កាន់តែប្រសើរណាស់ទៅទៀត ។

ជនណាបេះថែរក្សាខ្លួនឲ្យបានស្អាតជានិច្ច ជននោះពុំសូវមានជម្ងឺឡើយ ហើយមានអាយុក៏យឺនយូរផង ។

ប្រយោជន៍ឲ្យបានសុខសប្បាយខ្លួន ហើយឲ្យបានអាយុវែងផង ចូរអ្នកប្រតិបត្តិតាមដំបូន្មានខាងក្រោយនេះ ។

១– ចូរអ្នកដុសលាង សំអាតខ្លួនអ្នក ឲ្យបានស្អាតជាដរាប ចូរដុសលាងខ្លួននឹងសាប៊ូ បើយ៉ាងតិចណាស់ពីរដងក្នុង ១ អាទិត្យ ។

២– ចូរអ្នក លាងដៃនឹងសាប៊ូ នៅវេលាមុនបរិភោគអាហារ នឹងវេលាបរិភោគអាហាររួច ហើយនឹងមកពីបង្គន់វិញ ។ល។

៣– ត្រូវកាត់ក្រចកម្រាមដៃ-ម្រាមជើងឲ្យខ្លីត្រឹមសាច់ ហើយយកក្អែលក្រចកទាំងនោះចេញឲ្យស្អាតជាប្រក្រតី កុំយកម្រាមដៃទៅ

បៀមក្នុងមាត់ឲ្យសោះ ។ ចូរអ្នកកុំភ្លេចថាដៃនេះហើយ ដែលសំរាប់ចាប់កាន់ចំណីអាហារទាំងពួងបរិភោគ ។

៤– បើក្រចកយើងមានអាចម៍ទៅកខ្វក់ហើយ អ្នកយកទៅអេះខ្លួនអ្នក នឹងបណ្ដាលឲ្យកើតកមរមាស់ឬឲ្យកើតជាបូសផងក៏បាន ជួនកាលក៏ក្លាយទៅជាដំបៅអសោច បណ្ដាលឲ្យចាល់តែស្លាប់ខ្លួនផងក៏បាន ។

៥– បើអ្នកមានកើតជម្ងឺ ដូចបានសំដែងខាងលើនេះ ចូលប្រញាប់ប្រញាល់ទៅរកគ្រូពេទ្យឲ្យពិនិត្យមើលឲ្យ ហើយព្យាយាមថែរក្សាជម្ងឺនោះតាមបង្គាប់លោកគ្រូពេទ្យ លុះត្រាតែបានជាស្រឡះ ។

មេរៀនសង្ខេប.– យើងត្រូវសំអាតខ្លួនយើង ឲ្យស្អាតជាដរាប ប្រយោជន៍ឲ្យបានសេចក្ដីសុខក្សេមក្សាន្ត ។

១– ចូរអ្នកដុសលាងខ្លួនអ្នកនឹងសាប៊ូ បើហោចណាស់ ពីរដងក្នុងមួយអាទិត្យ ។

២– ចូរអ្នកលាងដៃអ្នក មុននឹងក្រោយបរិភោគអាហារ ហើយនឹងត្រឡប់មកពីបង្គន់វិញ ។

៣– ត្រូវកាត់ក្រចកឲ្យខ្លី ហើយដុសលាងឲ្យស្អាតកុំឲ្យមានក្អែលនៅក្នុងក្រចកនោះឡើយ ។

៤– កាលណាក្រចកអ្នកមានក្អែល ហើយយកទៅអេះវាបណ្ដាលឲ្យកើតកមរមាស់ឬឫស ដូនកាលវាបណ្ដាលឲ្យកើតដំបៅអសោច នាំឲ្យស្លាប់ខ្លួនក៏មាន ។

៥– បើអ្នកមានកើតជម្ងឺណាមួយ ដូចបានអធិប្បាយខាងលើនេះ ចូរប្រញាប់ទៅរកគ្រូពេទ្យព្យាបាលឲ្យ ។

ពាក្យសួរក្នុងមេរៀន ។ – យើងត្រូវធ្វើដូចម្ដេចខ្លះ ប្រយោជន៍ឲ្យបានជីវិតរស់នៅ ។ ពីព្រោះអ្វីបានជាយើងត្រូវសំអាតស្បែកយើង ។ បើស្បែកយើងមិនស្អាតតើវានឹងបណ្ដាលជាហេតុដូចម្ដេចខ្លះ ។ ដើម្បីឲ្យបានសុខសប្បាយខ្លួនតើយើងត្រូវប្រព្រឹត្តយ៉ាងណាខ្លះ ។ ល ។ ....

## មេរៀនជាគំរូ – អំពីឆ្អឹង

ប្រដាប់សំរាប់បង្រៀន ។ - សូមលោកគ្រូយកឆ្អឹង ទៅត្រាំក្នុងទឹកអម្បូរ (acide chloridrique) ឬត្រាំក្នុងទឹកខ្មេះ បានបីឬបួនថ្ងៃមុននឹងបង្រៀនមេរៀននេះ បើសិនជាធ្វើបាន ។ ឲ្យសិស្សរកឆ្អឹងជ្រូក ឬគោ គ្រប់យ៉ាង មានធំវែង - ខ្លី - សំប៉ែត ។ កាំបិត - អាណារ ។ ល ។ ...

# មេរៀន.–

**ពិនិត្យរូបរាងឆ្អឹង.–** ។– គេសំគាល់ឃើញថាឆ្អឹងទាំងឡាយ មិនដូចគ្នាទេ មានឆ្អឹងវែងមូលដូចជាឆ្អឹងដៃជើង ។ សំប៉ែតដូចជាឆ្អឹងស្លាបប្រចៀវក្ដី ដូចជាឆ្អឹងខ្នង ។

ឆ្អឹងនិមួយៗ ដូចជាឆ្អឹងជើងគោ មូលវែងហើយកំប៉ោងធំនៅចុង ដើមមានពណ៌សប្រផេះ ។

បើយើងយកកាំបិតកោសឆ្អឹងនេះ យើងនឹងឃើញមានសាច់យារ ជាសរសៃឆ្មារៗ ជាប់ចេញពីឆ្អឹងនោះ គឺសាច់សរសៃនេះហើយ ដែលរុំព័ទ្ធជុំវិញឆ្អឹងនិមួយៗ សំរាប់ជាអាហារទ្រទ្រង់ជីវិតឆ្អឹងឲ្យដុសធំធាត់ឡើងៗ

បើយើងយកកាំបិតទៅកោស ខាងចុងដើមឆ្អឹងនេះទៀត យើងឃើញជាប់សាច់ម៉្យាងទៀត សម្បុរសហើយទន់ ហៅថាឆ្អឹងខ្ចី (Cartilage) ។

យើងកាត់ពុះឆ្អឹងនេះជាពីរចំណែកតាមបណ្ដោយឆ្អឹងយើងសំគាល់ឃើញថាឆ្អឹងនេះមានបីចំណែក គឺៈ សាច់យារ - តួឆ្អឹងហើយនឹងបណ្ដូលឆ្អឹង - នៅខាងចុង ដើមឆ្អឹងនេះ មានឆ្អឹងរឹងព័ទ្ធជុំវិញ ចំណែកខាងក្នុងមាន ឆ្អឹងប្រហោងទុះៗ ដូចជាផ្កាថ្មហៅថាឆ្អឹងពពុស (Osspongieux) ដែល

មានសរសៃឈាមនៅពាសពេញក្នុងប្រហោងនោះ ៗ ឯឆ្អឹងសំប៉ែតនឹងឆ្អឹងខ្លីគ្មានបណ្តូលដូចជាឆ្អឹងវែងទេ ៗ

ព្យាករណ៍ .– ចូរយើងពិនិត្យមើលឆ្អឹង ដែលបានត្រាំក្នុងទឹកអម្បូរ (Acide chloridrique) ឬទឹកខ្មេះទុក ៦ ថ្ងៃមុន នោះយើងឃើញថាឆ្អឹងនេះ នៅរូបរាងដដែលប៉ុន្តែវាទន់ ឯសាច់យាវ ដែលរុំព័ទ្ធជុំវិញឆ្អឹងនោះមិនទន់ទេ ៗ បើយើងយកឆ្អឹងនេះទៅស្ងោរ ឲ្យបានចំនួន ៣ ឬ ៤ ម៉ោងសាច់យាវនេះនឹងផុយរលួយ ហើយស្អិតដូចជាជ័រកាវ ឬដូចជាសាហ្វាយស្ងោរ ៗ ឯឆ្អឹងមិនអាចនឹងរលួយឬទន់ក្នុងទឹកក្តៅឡើយ ៗ

បើយើងយកឆ្អឹងនេះទៅដុតក្នុងភ្លើងវិញ មានចំណែកឆ្អឹងខ្លះក៏ឆេះរលាយទៅ ឯចំណែកខ្លះទៀតគ្រាន់តែខ្មៅបទៅ ពីព្រោះចំណែកឆ្អឹងនេះ មានសិលាជាតិលាយផង ដោយហេតុនេះហើយ បានជាគេយកឆ្អឹង ទៅដុតរួចកិនកំទេច ទុកធ្វើជាដីដាក់ដំណាំ ៗ

ឆ្អឹងកូនក្មេងដែលនៅខ្ចី មិនទាន់មានសិលាជាតិទេ មានតែឆ្អឹងខ្ចីទន់ហើយយឺតដូចជាកៅស៊ូផង ៗ

ឆ្អឹងឯគណ្ឋិក.– (Les articulation)- មានឆ្អឹងខ្លះដូចជាឆ្អឹងលលាដក្បាល បន្តុំជាប់គ្នាយ៉ាងមាំ ដូចជាប្រអប់មួយ ពុំអាចនឹងកំរើកបាន

ឡើយ ៗ ឆ្អឹងខ្លះទៀតមានសន្លាក់ ដូចជាឆ្អឹងដើមដៃ កំភួនដៃ ឆ្អឹងទាំងនេះប្រទល់គ្នានឹងឆ្អឹងខ្ចី មានទឹករំអិលសំរាប់ជ្រើមសន្លាក់ទាំងនោះ ដើម្បីឲ្យកំរើកបានតាមត្រូវការ ហើយមានសរសៃបន្តជាប់ពីឆ្អឹងមួយទៅឆ្អឹងមួយ ៗ

មេរៀនសង្ខេប ·– ឆ្អឹងទាំងឡាយមិនដូចគ្នាទេ មានឆ្អឹងខ្លះវែង ដូចជាឆ្អឹងភ្លៅ ខ្លះខ្លីដូចជាឆ្អឹងខ្នង ខ្លះទៀតសំប៉ែតដូចជាឆ្អឹងស្មាប់ប្រចៀវ ឬឆ្អឹងក្បាល ៗ ឆ្អឹងវែងកំប៉ោងធំសង្ខាង អាចឲ្យប្រទល់គ្នាបានដោយងាយ ហើយមានឆ្អឹងទន់នឹងទឹករំអិល សំរាប់ជ្រើម ៗ ឆ្អឹងវែងមានបីចំណែក គឺសាច់យាដែលរុំព័ទ្ធជុំវិញឆ្អឹង តួឆ្អឹង ហើយនឹងបណ្ដូលឆ្អឹង ៗ ឯឆ្អឹងសំប៉ែតនឹងឆ្អឹងខ្លី គ្មានបណ្ដូលទេ មានតែប្រហោងរទុះៗ ៗ ដូចជាផ្កាថ្ម ដែលមានសរសៃឈាមនៅពាសពេញក្នុងរន្ធនោះ ៗ

ពាក្យសួរក្នុងមេរៀន ·– ឆ្អឹងយើងទាំងអស់មានរាងដូចគ្នាឬទេ ៗ ឆ្អឹងដៃ – ជើង ដូចម្ដេច ៗ ឆ្អឹងណាខ្លះដែលសំប៉ែត ៗ ដែលខ្លី ៗ ឆ្អឹងវែងមានប៉ុន្មានចំណែក ៗ នៅចុងឆ្អឹងទាំងសង្ខាងដូចម្ដេច ៗ ឆ្អឹងសំប៉ែតនឹងឆ្អឹងខ្លីមានបណ្ដូលឬទេ ៗល ៗ ...

## អនាម័យ

### អំពីជម្ងឺភ្នែក

ប្រដាប់សំរាប់បង្រៀន .– សុំរកគំនូររូបភាព ភ្នែកផ្សេងៗ — ភ្នែកកើតរោគអៀស៊ី – ភ្នែកកើតជម្ងឺ ភ្នែកមានខ្ទុះហូរចេញ – ថ្នាំពេទ្យផ្សេងៗ និងប្រដាប់សំរាប់ព្យាបាលជម្ងឺភ្នែក រួចនាំសិស្សពិនិត្យមើលឲ្យស្គាល់ច្បាស់ផង ។

មេរៀនសង្ខេប .– នៅប្រទេសឥណ្ឌូចិន ជម្ងឺភ្នែកមានច្រើនណាស់ តែងតែធ្វើឲ្យបណ្ដាជនឈឺជាខ្លាំង ។ ជម្ងឺនេះមានពីរយ៉ាង គឺ : ១- ជម្ងឺអៀស៊ីភ្នែក (Trachome); ២- ជម្ងឺភ្នែកក្រហមមានខ្ទុះហូរចេញ ជាពណ៌លឿងថ្លា (Conjonctivite purulente) ។

ជម្ងឺអៀស៊ីភ្នែក ជារោគមួយយ៉ាងសហ័ស បណ្ដាលឲ្យកើតអស់ចំនួន ៥០ ភាគក្នុងមួយរយភាគ. ហើយធ្ងន់ទៀតផង ៗ រោគនេះកើតមកអំពីដៃឬសំពត់កខ្វក់ដែលប៉ះពាល់ដល់ភ្នែក ជម្ងឺនេះឈឺបន្តិចម្ដងៗ យូរទៅបណ្ដាលឲ្យយើងខ្វាក់ភ្នែកបាន ។

ជម្ងឺភ្នែកក្រហមមានខ្ទុះហូរចេញ ជារោគឆ្លងខ្លាំងណាស់ទៅទៀត បើថែរក្សាមិនត្រូវ វានឹងឡើងដំបៅភ្នែក ជួនកាលវាបណ្ដាលឲ្យខ្វាក់អស់មួយជីវិតផង ។ ចូរអ្នកប្រយ័ត្ន ថែរក្សាភ្នែកឲ្យស្អាតជាដរាប កុំឲ្យមមង់ឬរុយដែលជញ្ជក់យកខ្ទុះភ្នែក មនុស្សឈឺភ្នែកមកពេមភ្នែកអ្នក កុំឲ្យប៉ះពាល់នឹងភ្នែកឈឺមានខ្ទុះហូរចេញ ។

បើអ្នកឈឺភ្នែកដូចបានអធិប្បាយរោគខាងលើនេះ ចូរប្រញាប់ទៅរកគ្រូពេទ្យឲ្យមើល ចូរអ្នកកុំប្រើឲ្យសោះ ថ្នាំណាដែលធ្វើឥតក្បួនខាត វានឹងនាំឲ្យអ្នកខ្វាក់ភ្នែកពុំខានឡើយ ។

## ពាក្យសួរក្នុងមេរៀន

... នៅប្រទេសដែលបណ្ដាជនប្រតិបត្តិតាមក្បួនអនាម័យ នឹងមានកើតជម្ងឺភ្នែកច្រើនឬទេ? ។ បណ្ដាជននៅប្រទេសយើង ប្រតិបត្តិតាមក្បួនអនាម័យទាំងអស់គ្នាឬទេ?។ ដូច្នេះបណ្ដាជននៅប្រទេសយើង មានកើតជម្ងឺភ្នែកច្រើនឬទេ? ។ ជម្ងឺភ្នែកមានប៉ុន្មានយ៉ាង? ។ យ៉ាងណាខ្លះ? ។ ដូចម្ដេចហៅថាជម្ងឺអៀស៊ីភ្នែក?។ ជម្ងឺភ្នែកមានខ្ទុះហូរចេញ ។ ចូរអ្នកអធិប្បាយអំពីជម្ងឺអៀស៊ីភ្នែក ។ អំពីជម្ងឺភ្នែកមានខ្ទុះហូរចេញ ។ល។

# អាទិកង្ហួន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី ១ .— ខ្លួនមនុស្ស

គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកពន្យល់សិស្ស ឬឲ្យសិស្សម្នាក់ដោះអាវ-ខោ ស្លៀកតែខោទ្រនាប់ហើយមកឈរនៅមុខតុសិស្ស ។ គ្រូចោទសួរហើយនាំសិស្សពិនិត្យមើលឲ្យជាក់ ។

ខ្លួនមនុស្សយើងមានប៉ុន្មានចំណែក? (មានបីចំណែក គឺៈ ក្បាល, ដងខ្លួន, និងអវយវៈលើក្រោម). ក្បាលមានឆ្អឹងច្រើនផ្គុំគ្នា ហើយគេចែកជាពីរចំណែកផ្សេងពីគ្នា គឺលលាដ៍ហើយនិងមុខ ។ លលាដ៍ក្បាលមានឆ្អឹងសំប៉ែត ឬកោងបន្ខំជាប់គ្នាមានសណ្ឋានដូចជា ប្រអប់មូលពងក្រពើហើយមានខួរនៅក្នុង ។ ឯឆ្អឹងមុខក៏បន្ខំគ្នាដែរ ហើយភ្ជាប់សាច់មុខផង ប៉ុន្តែមានរន្ធច្រើន ឯរន្ធពីរខាងលើ ហៅថាភ្នែក កណ្ដាលហៅថាច្រមុះ ហើយពៅក្រោមមានឆ្អឹងពីរ កោងអមប្រហោងមាត់គឺថ្គាម ហើយមានដុះធ្មេញនៅនោះ ។

ដូច្នេះឆ្អឹងក្បាលសុទ្ធតែបន្ទំជាប់គ្នាទាំងអស់ ហើយកំរើកមិនបានទេ មានតែថ្គាមក្រោមមួយដែលអាចកំរើកបាន ។

ដងខ្លួនយើងចែកជាប៉ុន្មានចំណែក? ចំណែកអ្វីខ្លះ? (ទ្រូងហើយនឹងពោះ) ។ អវយវៈមានប៉ុន្មាន? អវយវៈលើភ្ជាប់ទៅនឹងដងខ្លួនកន្លែងណា? (ត្រង់សន្លាក់ស្មា) ។ ដៃយើងបត់បានកន្លែងណាខ្លះ? (សន្លាក់ស្មា, កដៃ, ម្រាមដៃ,) បើប្រសិនណាជាគ្មានសន្លាក់អស់ទាំងនេះទេ ដៃយើងពុំអាចនឹងបត់ចុះឡើងបានឡើយ ។ អវយវៈក្រោមភ្ជាប់នឹងដងខ្លួនកន្លែងត្រង់ណា? អវយវៈក្រោមមានប៉ុន្មានចំណែក? សន្លាក់មានប៉ុន្មាន?

## សេចក្ដីសង្ខេប — ខ្លួនមនុស្ស.

ខ្លួនមនុស្សយើងមានបីចំណែកគឺក្បាល-ដងខ្លួន នឹងអវយវៈ ។ កភ្ជាប់ក្បាលទៅនឹងដងខ្លួន ។ នៅក្រោយដងខ្លួនមានឆ្អឹងខ្នង ។ ដងខ្លួនមានពីរចំណែក៖ ខាងលើគឺទ្រូង ខាងក្រោមគឺពោះ ។ មានអវយវៈបួនភ្ជាប់នឹងដងខ្លួន៖ ខាងលើពីរខាងក្រោមពីរ ។ ខ្លួនមនុស្សយើងមានសន្លាក់ជាច្រើន ប្រយោជន៍ឲ្យបត់ចុះឡើង ។

## មេរៀនលេខ១២ - អដ្ឋិសង្ខលិកៈ

ប្រដាប់សម្រាប់បង្រៀន - គ្រូត្រូវរកឆ្អឹងសត្វផ្សេងៗដូចជា ឆ្អឹងមាន់, ឆ្អឹងទន្សាយ, ឆ្អឹងដែលមានខួរនៅក្នុង ។

ទិដ្ឋភាពនៃឆ្អឹង - ឆ្អឹងមានពណ៌សព្រឿងៗ ។

បើយើងសង្កេតមើលឆ្អឹងភ្លៅមាន់ យើងនឹងឃើញថាឆ្អឹងនោះមានរាងទ្រវែងហើយស្តួចមានគ្រាមោងនៅចុងសងខាង៖

ឆ្អឹងណាដែលវែងៗមានជាតិទន់នៅខាងក្នុង ។ ជាតិទន់នេះហើយដែលគេហៅថាខួរក្នុងឆ្អឹង ។ ឆ្អឹងកពង់តូបមានទំហំទទឹងនឹងបណ្តោយស្មើគ្នា៖ ឆ្អឹងនេះគឺជាឆ្អឹងខ្លីៗ ។ ឆ្អឹងក្បាលរាងស្តើង៖ គឺជាឆ្អឹងសំប៉ែត ។

ក្នុងខ្លួនមនុស្សយើងមានឆ្អឹងវែង, ឆ្អឹងខ្លី នឹងឆ្អឹងសំប៉ែត ។ ឆ្អឹងវែងដូចជាឆ្អឹងដៃ, ឆ្អឹងខ្លីដូចជាឆ្អឹងកដៃ, ឆ្អឹងសំប៉ែតដូចជាឆ្អឹងលលាដ៍ក្បាល ។

ឆ្អឹងរឹង - យើងមិនអាចកាច់ឆ្អឹងមាន់ឬឆ្អឹងទន្សាយបាក់ទេ៖ ឆ្អឹងគោដែលធំៗ ក៏យើងមិនងាយដំបែកខ្ទេចខ្ទីនឹងញញួរបានដោយងាយដែរ ដូច្នេះយើងឃើញថាឆ្អឹងរឹងមែន ។

ហេតុអ្វីបានជាឆ្អឹងរឹងដូច្នេះ? បើយើងយកឆ្អឹងមួយទៅដុត នោះយើងនឹងឃើញថាឆ្អឹងមិនឆេះរលាយទាំងអស់ទេ ៣-៤ នាទីក្រោយមក បើយើងទាញឆ្អឹងចេញពីភ្លើងមក យើងនឹងឃើញផ្នែកឆ្អឹងដែលនៅសល់មានភាពដូចថ្មពណ៌សហើយស្រាល គឺជាតិថ្មកំបោរនេះហើយដែលជាហេតុនាំឲ្យឆ្អឹងរឹង ។

សេចក្ដីសង្ខេប — ឆ្អឹងមនុស្សយើងមានពងវែង, ខ្លី ឬសំប៉ែត ។ ឆ្អឹងមនុស្សចាស់រឹង ពីព្រោះមានជាតិថ្មកំបោរ ។ ឯចំណែកឆ្អឹងកូនក្មេងទន់ ហើយអាចទឹងផ្លាស់ក៏បានដោយងាយ ។ ប្រជុំឆ្អឹងទាំងអស់ហៅថា អដ្ឋិសន្ធិកៈ ។

ឆ្អឹងដែលសំខាន់ជាងគេក្នុងខ្លួនយើងគឺឆ្អឹងក្បាល, បន្ទាប់មកទៀត ឆ្អឹងខ្នង, ឆ្អឹងជំនីរ, ឆ្អឹងដៃ ឆ្អឹងជើង ។

មានឆ្អឹងច្រើន ដែលមានសន្លាក់ជាប់គ្នា៖ ដូចជាសន្លាក់ស្មា, សន្លាក់កែងដៃ, សន្លាក់កដៃ ។

អាទិត្យទី២ — ក្នុងអាទិត្យនេះសុំឲ្យគ្រូពន្យល់ពីការសំខាន់ៗ ក្នុងការទ្រទ្រង់ជីវិតយើងគឺ ការរំលាយអាហារ, ការដកដង្ហើម,

ការណាមរត់ក្នុងខ្លួនដើម្បីការបញ្ចេញវត្ថុមិនស្អាតមកក្រៅ (ញើស - លាមក ទឹកមូត្រ) ។

មើលសៀវភៅវត្ថុស្វាធ្យាយន៍ទំព័រទី ១២ ទៅដល់ទំព័រទី ១៦ ។

---

## មជ្ឈិមដ្ឋានទី ១

### វត្ថុស្វាធ្យាយន៍

អាទិត្យទី ១.– មេរៀនលេខ ១.– ខ្លួនមនុស្ស

សូមបង្រៀនតាមមេរៀនលេខ ១ សំរាប់អាទិកដ្ឋានហើយបន្ថែមសេចក្ដីលើខ្លះទៀត ។.

អាទិត្យទី ២.– មេរៀនលេខ ១.– អដ្ឋិសន្ធិលិក:

សូមមើលក្នុងសៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រទី ៦, ៧ ។

មេរៀនលេខ ២.– សាច់ដុំ

សូមមើលក្នុងសៀវភៅដដែលទំព័រទី ១១

---

# អាទិកដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១.– មេរៀនទី១– ការសំអាតខ្លួន

សុំមើលទស្សនាវដ្ដីឆ្នាំ ១៩៤៩–៥០ លេខ ១ ទំព័រទី ៤៧-៤៨-៤៩ ។

មេរៀនទី ២.– ការសំអាតសំលៀកបំពាក់

សុំមើលវិធីបង្ការរោគកុមារដ្ឋាននិងបរិវឌ្ឍណដ្ឋានទំព័រ ១៤ - ១៥ នឹង ២៨ - ២៩ - ៣០ - (ប្រការ ១)

អាទិត្យទី ២.– មេរៀនទី ១ ការសំអាតសំលៀកបំពាក់(ត)

សុំមើលវិធីបង្ការរោគថ្នាក់ដដែលទំព័រទី ៣១ - ៣២ (ប្រការ ២)

មេរៀនទី ២.– វិធីបង្ការរោគចំពោះផ្ទះ

ត្រូវរើសកន្លែងសង់ផ្ទះ នៅទីក្រុងសង់តាមវិថីធំ ៗ នៅស្រុកស្រែត្រូវរើសទីទួលនៅឆ្ងាយពីថ្លុកត្រពាំងប្រឡាយទឹក ៗ គួរសង់ផ្ទះឲ្យបានបែរមុខទៅខាងត្បូង ៗ ដើមឈើទាំងឡាយធ្វើឲ្យអាកាសបរិសុទ្ធហើយតែកុំឲ្យ

ដាំជិតផ្ទះពេក ដើម្បីទុកឲ្យពន្លឺព្រះអាទិត្យនិងអាកាសចូលក្នុងផ្ទះ ។ ត្រូវសង់ក្រោលគោ-ក្របី-សេះ-ទ្រុងជ្រូក-មាន់-ទានិងបង្គន់ឲ្យឆ្ងាយពីផ្ទះ ។ រាល់ព្រឹកត្រូវបើកទ្វារបង្អួចទាំងអស់ត្រូវបោសក្តារក្រាលថ្នម ៗ កុំឲ្យធូលីហុយឡើងត្រូវជូតគ្រឿងតុតាំងដោយសំពត់សើមត្រូវរើពូក-ខ្នើយ-ភួយ-កន្ទេល-មុងហាលថ្ងៃឲ្យបានញយ ៗ ។ ត្រូវបោសទីភូមិឲ្យបានស្អាតជានិច្ចហើយត្រូវដុតសំរាមចោល ។

សុភាសិត .- កន្លែងណាដែលមានពន្លឺព្រះអាទិត្យចូលកន្លែងនោះពុំសូវមានរោគទេ ។ ( សុំគ្រូធ្វើពាក្យសួរផងចុះ ) ។

---

# មជ្ឈិមដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១.- មេរៀនទី ២ និងទី ១ ការសំអាតខ្លួន

សុំមើលទស្សនាវដ្ដីឆ្នាំ ១៩៤៩-៥០ លេខ១ទំព័រទី ៩២-៩៣

អាទិត្យទី២ ៖- មេរៀន ទី ១- វិធីហាត់ប្រាណ

សុំមើលទស្សនាវដ្ដីឆ្នាំដដែលទំព័រ ទី ៩១-

## មេរៀនទី ២- ប្រយោជន៍កើតពីការហាត់ប្រាណ

សាច់ដុំដែលធ្វើការឡើងធំរឹងហើយខ្លាំង ការហាត់ប្រាណនាំគ្រឿងប្រដាប់ក្នុងខ្លួនយើងឲ្យដើរបានស្រួល នាំឲ្យឃ្លានបាយឲ្យអាហាររលាយបានដោយងាយឲ្យអាស្រ័យដំណេកបាន ។ កុមារណាស្រួលខ្លួនកុមារនោះមានទឹកមុខស្រស់មានបញ្ញាថ្លា អាចរៀនសូត្របានចំរើនមិនធុញទ្រាន់នឹងការសិក្សាឡើយ ។

---

# បរិវប្ឌណដ្ឋាន

## វិត្សាធ្យាយន៍

### អាទិត្យ ទី ១.- អំពីខ្លួនមនុស្ស

១ គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកបង្ហាញសិស្សឲ្យស្គាល់ចំណែកខ្លួនមនុស្ស រួចហៅសិស្សម្នាក់មកឈរពីមុខគ្នាសិស្ស ហើយឲ្យដោះ

ការចេញហៅសិស្សឯទៀតៗ ឲ្យពិនិត្យ មើលចំណែករូបកាយយើង ហើយចោទសួរបណ្ដើរ តាមរបៀបដូចមាននៅក្នុងសៀវភៅ វត្ថុស្វា-ធ្យាយន៍បរិច្ចណដ្ឋានទំព័រទី ៣ នឹងទី ៤ មានទាំងពាក្យសួរ នឹងមេរៀនសង្ខេបសំរាប់ឲ្យសិស្សរៀនស្រាប់ហើយ ។

២ អដ្ឋិសន្ធិលិក: ក្បាលដងខ្លួននឹងអវយវ:

បើគ្មានផ្ទាំងគំនូរទេ ត្រូវនាំសិស្សឲ្យមើលគំនូរក្នុងសៀវភៅ រួចឲ្យស្ទាបបង្ហាញលើខ្លួនសិស្ស ដែលដោះអាវឈរពីមុខគេនោះ ហើយឲ្យប្រាប់ឈ្មោះឆ្អឹង ទ្រង់ទ្រាយនឹងទំហំឆ្អឹងហើយនឹងប្រយោជន៍ឆ្អឹង ហេតុដូចម្ដេចបានជាមានឆ្អឹងខ្លះមូល ឆ្អឹងខ្លះសំប៉ែត ឆ្អឹងខ្លះវែង ឆ្អឹងខ្លះខ្លី? សុំមើលសេចក្ដីនេះនៅក្នុងសៀវភៅដដែលទំព័រទី ៥ នឹង ៦ ។

## អាទិត្យទី ២ អំពីឆ្អឹងសន្លាក់ឬគណ្ឋិក

សុំមើលក្នុងសៀវភៅដដែលទំព័រទី ៨ នឹង ៩ ។

## អំពីសាច់ដុំ

សុំមើលក្នុងសៀវភៅដដែលទំព័រទី ១០ ។

# បរិបូណ៌ដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យ ទី ១.- វិធីហាត់ប្រាណ

ឲ្យសិស្សពិនិត្យមើលរូបរាងកាយអ្នកស្រែចំការនឹងអ្នកធ្វើការរាជការ តើខុសគ្នាយ៉ាងណា? ដោយសារអ្វី? បើដូច្នេះត្រូវធ្វើដូចម្ដេច? ឲ្យបានរូបកាយធាត់ធំមាំមួន ត្រូវហាត់ប្រាណនៅទីណា? ក្នុងពេលហាត់ប្រាណមិនត្រូវធ្វើព្រាយមាយឲ្យសោះ ។ ត្រូវខំប្រឹងប្រែងឲ្យមាំមួនទើបបានរូបកាយនោះសមល្អហើយធ្មឹងពេកក៏មិនអាចនឹងរៀនបានផង ។

ម្យ៉ាងទៀតត្រូវហាត់ដើរក្នុង១ថ្ងៃឲ្យបាន២ម៉ោងដកពីព្រលប់ ក្រោកពីព្រលឹម ឲ្យខ្យល់អាកាសចូលក្នុងដំណកឲ្យបរិបូណ៌ ។

មេរៀនសង្ខេប សុំគ្រូតែងផងចុះ ។

### អាទិត្យទី២.- ការសំអាតខ្លួនប្រាណ

កាលណាឯងរត់លេងហាលក្ដៅ ឯងនឹងឃើញមានអ្វីនៅលើស្បែក

ឯង ? ឲ្យសិស្សយកដៃជូតមុខវាយកមកមើល តើវាឃើញមានអ្វី : ញើសស្អិតដូចប្រេង ៗ ឲ្យវាលិទ្ធមើលតើទឹងដឹងដូចម្តេច ? ប្រៃ ៗ ហិតក្លិនមើល ៗ ធុំអាក្រក់ ៗ កាលណាធូលីហុយមកប៉ះនឹងបង្កើតទៅជាអ្វី ? ក្អែល ៗ ក្អែលបណ្តាលឲ្យបានយ៉ាងណា ? បុករន្ធញើសមិនឲ្យចេញ ៗ មនុស្សណាដែលញើសមិនចេញស្រួលត្រូវធ្វើដូចម្តេច ? ៗ

មេរៀនសង្ខេប :– មនុស្សត្រូវថែរក្សាស្បែកឲ្យស្អាត ពីព្រោះស្បែកនេះហើយដែលជាប្រដាប់សម្រាប់បញ្ចេញញើសដែលជាវត្ថុសៅ–ហ្មងដល់រូបកាយយើង ហេតុនេះត្រូវដុសលាងនឹងសាប៊ូជារឿយ ៗ ត្រូវលាងដៃឲ្យស្អាត ៗ ក្រចកដៃ ក្រចកជើងត្រូវកាត់ឲ្យខ្លី ៗ

---

## កុមារដ្ឋាន

### វិត្តសាធ្យាយន៍

#### អាទិត្យទី១.– អំពីស្តាំឆ្វេង

ការបង្រៀនក្នុងខែកញ្ញានេះ សិស្សនៅថ្នាក់កុមារដ្ឋានពុំទាន់ចេះ

មើលបេះសរសេរនៅឡើយ សុំគ្រូហ្វឹកហ្វឺនឲ្យចាំស្ទាត់តែខាងវិធីហាត់ ហើយនឹងប្រាប់ពន្យល់ឲ្យចាំប្រាកដផង ។

មេរៀនលេខ១ អំពីស្តាំ - ឆ្វេង

នាំសិស្សឲ្យពិនិត្យមើលឲ្យដឹងស្តាំឆ្វេង ។

ឯងមានដៃប៉ុន្មាន ? ដៃទាំងពីរនេះមានឈ្មោះឬទេ ? ដៃនេះឈ្មោះដូចម្តេច? ដៃនេះទៀតឈ្មោះអ្វី ? ដៃទាំង២ដៃណាធ្វើការច្រើនជាងគេ ? ឲ្យសិស្សលើកដៃទាំងអស់គ្នាតាមគ្រូបោច ។

នៅខាងស្តាំឯងមានអ្វី ? បើឯងបែរមុខទៅខាងជើង ទិសណានៅខាងស្តាំឯង ? ទិសណានៅខាងឆ្វេងឯង ? ទិសណានៅខាងមុខឯង ? ទិសណានៅខាងក្រោយឯង ? បើឯងដើរតាមផ្លូវ ត្រូវដើរខាងណា ? ចុះបើបររទេះក្តី ជិះសេះក្តី ត្រូវកាន់ខាងណា ? ពីព្រោះអ្វីបានជាគេឲ្យប្រកាន់ខាងស្តាំយ៉ាងនេះ? (កុំឲ្យជល់ទង្គិចគ្នាវេលាដែលជួបគ្នា.) ចុះបើឯងជិះទូកឬកប៉ាលចុះបណ្តោយតាមទឹក ខាងណាដែលហៅត្រើយស្តាំ ? ត្រើយណាដែលហៅត្រើយឆ្វេង ។ល។

## មេរៀនចាំមាត់.– សេចក្តីសង្ខេប

ត្រូវឲ្យស្គាល់ស្តាំឆ្វេង ដៃស្តាំធ្វើការច្រើនជាងដៃឆ្វេង ទៅណាមក

ណាត្រូវកាន់ខាងស្តាំផង ដើម្បីជៀសវាងកុំឲ្យទង្គិចគ្នា នៅវេលាដែលជួបគ្នា ។

## អាទិត្យទី ២.– អំពីច្បាប់ដើរនៅផ្លូវ

សុំគ្រូរំលឹក សិស្សពីមេរៀនមុន ហើយនាំសិស្សមកច្រាបរបៀបដើរហើយនឹងឆ្លងកាត់ផ្លូវនៅផ្លូវមុខថ្នាក់ ។

១– វេលាណាដែលយើងនៅផ្លូវ យើងត្រូវចេះច្បាប់ដើរ ពីព្រោះផ្លូវតែងមាន គ្រោះថ្នាក់ជានិច្ច លើរូបអ្នកដែលមិនប្រយ័ត្ន ។ នៅទីក្រុង នៅផ្លូវនិមួយៗ មានរទេះតិចឬច្រើន ? យើងត្រូវដើរដូចម្ដេចតាមផ្លូវ ? វេលាឆ្លងកាត់ផ្លូវត្រូវធ្វើដូចម្ដេច ? វេលាឆ្លងផ្លូវមានរទេះបរមកចំខ្លួន ត្រូវជៀសដូចម្ដេច ? ទៅខាងណា ? មិនត្រូវតក់ស្លុតដោយភ័យ ត្រូវគិតមើលឲ្យស្រួលបើគួរឈប់ត្រូវឈប់ឲ្យរទេះជៀសវិញ. បើចង់គេចត្រូវគេចទៅខាងស្តាំជានិច្ច ។

២– សេចក្តីចោទសួរ.– បើជិះទោចក្រយានត្រូវប្រកាន់ខាងណា? បើចង់បត់ឆ្វេងស្តាំត្រូវធ្វើដូចម្ដេច? ។ល។

៣– សេចក្តីសង្ខេប.– ទោះដើរនៅផ្លូវ ថ្នល់ក្តី ជិះកង់ក្តី ឬជៀសរទេះឡានក្តី ក៏គប្បីប្រកាន់ស្តាំជានិច្ច ដើម្បីជៀសវាងគ្រោះថ្នាក់. ។

# កុមារដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១ – អំពីការសំអាតខ្លួនប្រាណ

ក្នុងថ្ងៃនេះ ដោយសិស្សពុំទាន់ចេះមើលចេះសរសេរនៅឡើយ គ្រូតោងបង្ហាញតែខាងវិធីហាត់ឲ្យមែនទែន ហើយនឹងចោទមាត់ទទេឲ្យចាំប្រាកដក្នុងការសំអាតខ្លួន

១ គ្រូចាត់សិស្សម្នាក់ដែលមិនស្អាតឲ្យទៅឈរនៅមុខសិស្សឯទៀតរួចហើយនាំសិស្សឯទៀតឲ្យពិនិត្យខ្លួនប្រាណ ដៃជើងមុខមាត់ឲ្យគ្រប់កន្លែង ។ល។

សិស្សដែលឈរនេះឈ្មោះអ្វី ? នៅត្រង់ណាទៀតដែលមានក្អែលច្រើន ? ឯងធុំក្លិនអ្វីកាលឯងមកឈរជិតវា ?

ក្អែលនៅលើស្បែកបិទរន្ធអ្វី ? ក្មេងស្មោកគ្រោកដូចចៅនេះបានសេចក្ដីសុខសប្បាយឬទេ ? នាំបង្កើតរោគអ្វី ? ។ល។

ត្រូវធ្វើដូចម្ដេចទើបស្អាត ? ឯងត្រូវងូតទឹកដូចម្ដេច ? កាលណាងូតទឹកត្រូវដុសសាប៊ូខ្លួនប្រាណដូចម្ដេច ? ត្រូវប្រើអ្វីទើបជ្រះក្អែលល្អ ?

បើគ្មានសាប៊ូឯងត្រូវយកអ្វីប្រើជំនួស ? យ៉ាងហោចក្នុង ១ អាទិត្យត្រូវដុសខ្លួនប្រាណប៉ុន្មានដង ? ការសំអាតខ្លួនប្រាណមានប្រយោជន៍ដូចម្ដេចខ្លះ ? ។ល។

២ – សេចក្ដីសង្ខេប – ប្រយោជន៍សុខសាន្ត ត្រូវសំអាតប្រាណឲ្យបានហ្មត់ហ្មង ដុះសព្វដៃជើង គ្រប់សារពាង្គផង ទើបរួចកន្លង ពីការស្មោកគ្រោក ។ ចូរចាំកុំភ្លេច មនុស្សណាគគ្រេច មិនដែលអ្នកផង ចូលចិត្តបង់ជិត ស្នេហ៍ស្និទ្ធសាសង នឹងមនុស្សនេះហោង ដោយខ្ពើមរអើម ។

## អាទិត្យទី ២ របៀបប្រើសាប៊ូ

កាលណាគេបោកលាងសំលៀកបំពាក់តែនឹងទឹកទទេ គេនឹងបានស្អាតឬទេ បើដូច្នេះខ្លួនប្រាណយើងក៏ត្រូវដុសលាងទឹកសាប៊ូដែរ កាលណាឯងជូតទឹកសាប៊ូនាំឲ្យកាត់ក្អែលបំបាត់ក្លិនអាក្រក់ ដែលដុសសំលៀកបំពាក់នឹងសាប៊ូល្អ គេដុសខ្លួនប្រាណនឹងសាប៊ូក្រអូប វេលាដែលដុសសាប៊ូត្រូវដុសឲ្យយូរសឹមលាងទឹកចេញ ។

## អំពីទឹកឆ្អិន

ធ្វើដូចម្ដេចឲ្យបានទឹកឆ្អិនសុទ្ធផឹកតាមត្រូវការ?

យើងយកថ្នាំប៉េរម៉ង់តាណាត មកលាយនឹងទឹកក៏បានដែរ ប៉ុន្តែអ្នកស្រុកពុំធ្លាប់ប្រើ តាមធម្មតា គេយកទឹកមកដាំឲ្យពុះចំនួន ១៥ មីនុត ទើបយកមកផឹក ការទំលាប់ផឹកទឹកក្ដៅនេះ នាំឲ្យយើងជៀសវាងជម្ងឺច្រើនប្រការ កាលណាស្រុកមានជម្ងឺ ។ យើងចង់ឲ្យទឹកនោះមានក្លិនរសជាតិល្អ ត្រូវធ្វើដូចម្ដេចទៀត ? យួនចិនប្រើទឹកតែជាប់ជាធម្មតា ។ ខ្មែរយើងក៏ប្រើដែរ ខ្លះប្រើទឹកឫសជ្ជិត ស្មៅរុក្ខឫសដូងព្រះ ។ ទំលាប់យ៉ាងនេះជាការសំខាន់ ព្រោះភេសជ្ជៈនេះមានគុណប្រយោជន៍ហើយថ្លៃតិចផង ។

---

## លោកនីតិ

សំរាប់ថ្នាក់ទាំង ៤ ពីបវិច្ចណដ្ឋានទៅដល់ឧត្តមដ្ឋាន

### អាទិត្យដំបូង - ប្រទេសកម្ពុជា

កម្ពុជាគឺជាដែនដីមួយក្នុងសកលលោក ជាប្រទេសរបស់ខ្មែរមានព្រះមហាក្សត្រិយ៍សោយរាជ្យ ។ របៀបរាជការក៏មានគ្រប់គ្រាន់ដូចប្រទេសដទៃដែរ គឺមានរដ្ឋសភា - ក្រុមព្រះរាជអាណាចក្រ

រដ្ឋាភិបាលនិងតុលាការ ។ រដ្ឋសភាគឺទីប្រជុំអ្នកតំណាងរាស្ត្រ សម្រាប់ប្រឹក្សាច្បាប់ទំនុកបំរុងឬគ្រប់គ្រងរដ្ឋ ។ ក្រុមព្រះរាជអាណាចក្រត្រូវពិនិត្យ និងឲ្យយោបល់អំពីសេចក្តីព្រាងច្បាប់ និងស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមរួចហើយ រដ្ឋាភិបាលគឺគណៈរដ្ឋមន្ត្រីនៃព្រះមហាក្សត្រិយ៍ គឺមន្ត្រីទំនុកបំរុងប្រទេសមានចំនួនយ៉ាងច្រើនត្រឹមដប់ពីរ-រូប រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង តុលាការគឺក្រសួងជំរះក្តីស្ទង់ថ្លឹងការមិនឲ្យល្អៀង ។

ពាក្យសួរ - ប្រទេសកម្ពុជា ជាប្រទេសរបស់ជាតិណា ? ព្រះមហាក្សត្រិយ៍ព្រះនាមអ្វី ? របៀបរាជការអ្វីខ្លះ ដែលអ្នកស្គាល់ ? រដ្ឋសភាសម្រាប់ធ្វើអ្វី ? ។ល។

មេរៀនសង្ខេប- ប្រទេសកម្ពុជា ជាប្រជាជាតិមួយក្នុងសកលលោកមានមហាក្សត្រិយ៍សោយរាជ្យ ។ ឯរបៀបរាជការក៏មានគ្រប់គ្រាន់ពេញលេញដូចប្រទេសដទៃដែរ មានរដ្ឋសភាក្រុមព្រះរាជអាណាចក្ររដ្ឋាភិបាលនិងតុលាការ ។

អាទិត្យក្រោយ ·- អំពីភូមិនិងឃុំ

តំបន់ណាដែលមានប្រជុំផ្ទះលំនៅច្រើនហៅថាភូមិ ។

ភូមិរួមគ្នាពីរឬបីឡើងទៅបានជាឃុំមួយ មានមន្ត្រីម្នាក់ជានាយកត្រួតត្រាហៅថាមេឃុំ ។ នៅក្រុងភ្នំពេញគេចែកឃុំជាសង្កាត់ៗ ។ អ្នកត្រួតត្រាសង្កាត់និមួយហៅថាមេសង្កាត់ ។

មេឃុំមានស្មៀនទីជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ មេឃុំជាអាណាព្យាបាលលើឃុំ ជួយទំនុកបំរុងរាស្ត្រឲ្យបានសន្តិសុខ ។

ពាក្យសួរ .– អ្នកនៅភូមិណា ពីព្រោះអ្វីបានគេហៅឈ្មោះភូមិអ្នកយ៉ាងដូច្នេះ ? ភូមិអ្នកតូចឬធំ ? មានមនុស្សនៅប្រហែលប៉ុន្មាននាក់ ពីព្រោះអ្វីបានជាគេសាងភូមិអ្នកនៅទីនោះ ? អ្នកណាត្រួតត្រាលើភូមិអ្នក ? យ៉ាងដូចម្តេចដែលហៅថាឃុំ ? មេឃុំធ្វើអ្វីខ្លះ ? ។ល។

មេរៀនសង្ខេប.– ភូមិគឺតំបន់ដែលមានប្រជុំផ្ទះសំនៅច្រើន ភូមិណាធំទូលាយមានផ្លូវ កាន់គ្នាទៅវិញទៅមក បានដោយងាយភូមិនោះមានមនុស្សនៅច្រើនជាងគេ ។

ឃុំគឺទីប្រជុំភូមិច្រើនឬតិចតាមបញ្ញត្តិរាជការរដ្ឋបាល នាទីក្នុងអំណាចមេឃុំម្នាក់ ។ មេឃុំជាអាណាព្យាបាលការពាររាស្ត្រឲ្យបានសន្តិសុខ មានស្មៀនទីជំទប់ជួយធ្វើការទារពន្ធដារពីរាស្ត្រ តាមច្បាប់បញ្ញត្តិ

# មេសូត្រត់មាត់

(សំរាប់គ្រប់ថ្នាក់)

## ១– ប្រដាប់ប្រដាររបស់កូនសិស្ស

ពួកសិស្សសិក្សា   នៅសព្វសាលា   ត្រូវមានប្រដាប់
សំរាប់សូត្ររៀន   ទើបស្រួលចេះឆាប់   បើគ្មានប្រញាប់
ប្រញាល់ស្វែងរក ៗ   សិស្សអើយចូរចាំ   ចូរបរិកម្ម
យើងផ្តាំឲ្យរក   សៀវភៅមើលមួយ   ចូរអ្នករក
ជាវឲ្យបានមក   សំរាប់ហាត់អាន ៗ   សៀវភៅសរសេរ
ចូរតែគិតគ្នេរ   រិះរកឲ្យមាន   ព្រោះជាប្រដាប់
សំរាប់អ្នករៀន   សរសេរឲ្យបាន   អក្សរល្អឆាប់ ៗ
បើគូសឬគូរ   តាមបែបគំនូរ   ដែលគ្រូលោកប្រាប់
បន្ទាត់ខ្មៅដៃ   ទើបគូសគូរឆាប់   ព្រោះត្រូវប្រញាប់
ដល់ពេលវេលា ៗ   ម្យ៉ាងទៀតត្រូវរក   ជ័រលុបមួយមក
ក្រដាស់ផ្តិតណា   សំរាប់លុបកែ   តម្រែអក្ខរា
ប្រឡាក់ចូរបា   នាងផ្តិតឲ្យស្អាត ៗ   ទឹកខ្មៅមួយទៀត

ចូរអ្នកខ្លីឃ្លាត រកកុំកន្ទុង ព្រោះជាប្រដាប់
ជាប់ចាប់ទាក់ទង ជាមួយនឹងដង ព្រមទាំងស្លាបណា ។
បើមានសត្វហើយ ចូរកែវគ្រាណាត្រើយ ចាំថែរក្សា
ចូរកុំឲ្យបាត់ ភ្លាត់ខ្ចាត់ទៅណា អាណិតមាតា បិតាអ្នកផង ។

ពាក្យពន្យល់= បរិកម្ម=ការទទេន្ទេញ ។ ពន្ធក = ដែលជាទី ស្នេហា ។ ជាវ= លក់ឬទិញ ។ អាន= មើល ថាតាមអក្សរ ។អក្ខរា= អក្សរ ។

## ២ - សាលារៀននៅភូមិខ្ញុំ

នៅក្នុងភូមិខ្ញុំ សាលាមួយធំ មានបីបន្ទប់
បន្ទប់មួយៗ មានគ្រូសិស្សគ្រប់ គ្រូម្នាក់ជាម្ចប់
នៃសិស្សច្រើនគ្នា ។ ថ្នាក់ដែលខ្ញុំរៀន បរិច្ចណាផ្កា
ខាងស្តាំជិតទ្វារ ដែលខ្ញុំចូលទៅ សំដៅសាលា
គេសង់នៅនា ទីដីមួយធំ ។ នៅមុខសាលា
មានដាំសួនផ្កា ជាទីមនោរម្យ នឹងមានដើមឈើ
ខ្លះតូចខ្លះធំ សាខាស៊ុមទ្រុម មានម្លប់ត្រឈៃ

ខាងក្រោយសាលា ល្វឹងល្វើយទីធ្លា ធំធេងពេកក្រៃ
ខ្ញុំរៀនចំណេះ ហាត់ប្រាណសព្វថ្ងៃ បានស្រួលសរសៃ
សុខស្រួលក្សេមក្សាន្ត ។ ពេលឈប់សម្រាក ខ្ញុំនាំពួកបក្ស
ជាមិត្រកល្យាណ លេងក្នុងធ្លាធំ រាំហើយកំសាន្ត
ទើបពួកខ្ញុំបាន សប្បាយចិត្តអើយ ។

ពាក្យពន្យល់ - មនោរម = (ម.ថ. ម៉ៈនោរំ) ដែលជាទីរីករាយចិត្ត, ដែលគួរឲ្យសប្បាយចិត្ត ។
ក្សេមក្សាន្ត = ដែលមានសេចក្តីសុខសាន្ត ។
ពួកបក្ស = (បក្ស. ម.ថ. ប៉ាក់) ចំនួនគ្នាច្រើន ដោយឡែកផ្សេងៗ ។ កល្យាណ = មានលំអដ៏ប្រសើរគួររាប់អាន ។

## ៣ - ខ្លួនមនុស្ស

មនុស្សយើងបើសិនជាបំបែក គិតគូរតាមផ្នែកបីភាគា
ក្បាលមួយខ្លួនមួយតភ្ជាប់គ្នា ដៃជើងក៏ជាមួយចំណែក ។
លើក្បាលមានសក់ដុះស្កាញស្កុក ខាងមុខមានមុខប្រមុះភ្នែក

ត្រចៀកសន្ធារបែងបំបែក ទើបបានកន្លែកញែកពីគ្នា ។
មាត់នៅខាងមុខក្រោមច្រមុះ សំរាប់ភ្លក់រសជាតិអាហារ
ច្រមុះមានរន្ធពាំងទ្វេហារ ហិតក្លិនគន្ធា ឬ ស្អុយក្តី ។
ភ្នែកអាចសំឡឹងឲ្យដឹងជាក់ ស្គាល់រូបប្រត្យក្សប្រុស ឬ ស្រី
ដឹងសព្ទមគ្គាដឹងវិថី ខ្ពស់ទាបចាស់ថ្មី ឬ តូចធំ ។
ត្រចៀកសំរាប់ឮសូរសៀង ប្រគំបម្រៀងកូតឬផ្លុំ
សំឡេងចាស់ក្មេងតូចឬធំ ត្រចៀកក៏គាំពារទាំងអស់ ។
ដងខ្លួនមានទ្រូងនៅខាងមុខ ក្រោមទ្រូងនោះទុកកន្លែងពោះ
ដែលទន់គ្មានឆ្អឹងបន្តិចសោះ សន្មតឲ្យឈ្មោះពោះពេញទី ។

ពាក្យពន្យល់ – ភាគា = ភាគ ចំណែក ។ សន្ធារ = គ្រឿងប្រុង ។
ទ្វេហារ ( ទ្វេ = ពីរ ) ។ គន្ធា = គ្រឿងក្រអូប ។
ប្រត្យក្ស = ( ម . ថ . ប្រត្យក ) ដែលជាក់,
ប្រាកដ , ច្បាស់ ។ មគ្គា = ផ្លូវ ។

## ៤- ខ្លួនមនុស្ស (ត)

ដងខ្លួនមានហត្ថបាទា បន្តភ្ជាប់គ្នាឥតឃ្លាតទេ

ក្នុងដៃមួយៗបើរិះរេ　　ពិនិត្យគិតគ្នេរឃើញសព្វគ្រប់ ៗ

មានដើមកំភួនមានភួនផង　　ត្លួពីរកាប់រងភ្ជាប់ម្រាមដប់

ដៃនេះឯងហើយយើងកុំថប់　　អាចកាន់សព្វគ្រប់តាមការគួរ ៗ

ឯជើងមានភ្លៅនៅក្រោមខ្លួន　　មានស្មងកំភួនជង្គង់ត្លួ

សំរាប់ដើររត់ឬដើរស្ទួរ　　មិនបាច់ចាំគួរតាមកាលសម ៗ

ក្នុងខ្លួនមានសាច់ឈាមសរសៃ　　មានឆ្អឹងវែងខ្លីមានតូចធំ

បីរយកំណាត់សន្ធារផ្គុំ　　ពួតផ្គុំប្រជុំជារាងកាយ ៗ

## ពាក្យពន្យល់ - ហត្ថបាទ - ដៃជើង ៗ

សន្ធារ - ប្រមូលផ្តុំ ៗ

## ៥- បរិវេសនកាលនៃថ្នាក់រៀន

ទិវនព្រឹកស្អែកហ្នឹង　　ខ្ញុំវិលវិញចូលរៀនហើយ

ខ្ញុំមិននៅកន្តើយ　　ព្រោះផុតហើយកាលកំសាន្ត ៗ

គឺពេលដែលសំរាក　　នាំលំបាកខ្វាត់បាកប្រាណ

សប្បាយអប្រមាណ　　ម្សិលមិញបានខ្ទង់ផុតហើយ ៗ

ក្នុងទិនមុខនេះ　　ខ្ញុំក្រោកក្រេសពុំយូរឡើយ
លុះខ្ញុំក្រោកឡើងហើយ　　រៀបចំខ្នើយកន្ទេលមុង ។
តាក់តែងសព្វាង្គរួច　　ទើបក្របួចចាប់គ្រឿងប្រុង
ក្របួចនៅខាងក្នុង　　ពេញកំពុងគ្រឿងសិក្សា ។
មកស្ពាយលើអង្សៈ　　លុតបាទៈលើកហត្ថា
ប្រណម្យបង្គំលា　　នូវមាតាបិតាផង ។
ទើបចេញពីគ្រឹះស្ថាន　　សំដៅប្រាណត្រង់តែម្តង
ព្រោះចិត្តជាប់សុទ្ធចង　　ខ្លាចកន្លងពេលវេលា ។
នៅតាមវិថីនោះ　　មានស្រីប្រុសចំរុះគ្នា
សុទ្ធតែអ្នកសិក្សា　　ជជែកគ្នាឮរងំ ។
បណ្តើរគ្នាត្រសង　　កងរំពងទាំងតូចធំ ។
ខ្លះដើរដោយក្រុម ៗ　　ខ្លះស៊ីនំនៅហត្ថា ។

ពាក្យពន្យល់.— បវេសនកាលនៃថ្នាក់រៀន – ពេលចូលរៀនជាថ្មីនៃថ្នាក់រៀន ។ ទិវ័ន – (ម.ថ. ទិវ៉ាន់) ថ្ងៃ ។ អប្រមាណ ឬ អប្បមាណ – ដែលប្រមាណមិនបាន ។ ទិនមុខ – (មុខនៃថ្ងៃ) គឺវេលាបំព្រាង,

ព្រឹកព្រាង ។ សព្វាង្គ = រាងកាយទាំងមូល ។

អង្សៈ = ស្មា ។ បាទៈ (ម.ថ.បាទាក់)= ជើង ។

ហត្ថា = ដៃ ។ បំរុះ ឬ បម្រុះ = ដែលលាយ

ឡំគ្នា ។

## ៦ - បវេសនកាលនៃថ្នាក់រៀន (ត)

ខាងមុខសាលាខ្ញុំ　　សិស្សប្រជុំជិតមាត់ទ្វារ
ចាំដល់វេលា　　ទាំងអស់គ្នាឈររង់ចាំ ។
បំណែកខាងខ្ញុំវិញ　　ជួបសម្លាញ់មិត្តកល្យាណ
ដែលប្រាស់ឃ្លាតចាកឋាន　　យូរខែខានជួបគ្រា ។
ទើបខ្ញុំសួរដំណឹង　　សុខទុក្ខនឹងមិត្តពល់គ្នា
រីករាយឥតឧបមា　　ដូចវង្សាជាប់លោហិត ។
លុះដល់ម៉ោងប្រាំបី　　សូរជួងថ្មីគេវាយពិត
សូរនេះជាកំរិត　　ដែលយើងគិតតែសិក្សា ។
ទើបខ្ញុំនឹងមិត្តភក្តិ　　សូរជួងជាក់កម្មា
ចូលដល់ក្នុងសាលា　　លើកហត្ថាបន្ទន់កាយ ។

ប្រណម្យថ្វាយបង្គំ ព្រោះគ្រូខំដោយរីករាយ
ដែលបែកយូរវែងឆ្ងាយ ទើបវិលកាយទៅដើមម៉ា ។
លុះខ្ញុំអង្គុយស៊ប់ ចិត្តខ្ញុំឈប់កង្កវិទ្យា
ខ្ញុំខំតម្រង់ស្មារ តីចាំស្តាប់ពាក្យពេចន៍គ្រូ ។
ខ្ញុំតាំងចិត្តជាថ្មី ភ្នែករំពៃមិនបង្វែរ
មើលក្តារខៀនតាំងគ្រូ ប្រុងស្តាប់គ្រូមានប្រសាសន៍ ។

ពាក្យពន្យល់ –

ភក្ត្រា = មុខ ។ លោហិត = ឈាម ។
មិត្រភក្តិ = មិត្រដែលស្លូតត្រង់, ស្មោះត្រង់ ។

រោងពុម្ពខ្មែរ